# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
# អគ្គនាយកដ្ឋានការងារ
# នាយកដ្ឋានពេទ្យការងារ

# កម្រងព័ត៌មានជាតិលើកទី២
# ស្តីពី
# សុវត្ថិភាព និងសុខភាពការងារ

ឆ្នាំ២០២២

គាំទ្រដោយៈ មូលនិធិរាជរដ្ឋាភិបាលជប៉ុន តាមរយៈគម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់ នៃអង្គការអន្តរជាតិខាងការងារ ( ILO/Japan OSH Project)

# មាតិកា


**អារម្ភកថា** ........................................ ១

**សេចក្តីថ្លែងអំណរគុណ** ........................................ ៣

**អក្សរកាត់** ........................................ ៥

I. **សាវតា** ........................................ ៧

**១. ព័ត៌មានភូមិសាស្ត្រ និងប្រជាសាស្ត្រ** ........................................ ៧

**២. អំពីស្ថានភាពស្តីពីសុវត្ថិភាព និងសុខភាពការងារ** ........................................ ៨

II. **ក្របខណ្ឌច្បាប់ និងលិខិតឧបករណ៍ពាក់ព័ន្ធនឹង សុវត្ថិភាព និងសុខភាពការងារ** ........................................ ៩

**១. ឯកសារយោងនៅក្នុងរដ្ឋធម្មនុញ្ញ** ........................................ ៩

**២. ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ** ........................................ ៩

២.១. ច្បាប់ស្តីពីការងារ ........................................ ៩

២.២. ច្បាប់ស្តីពីរបបសន្តិសុខសង្គម ........................................ ៩

២.៣. ច្បាប់ស្តីពីសំណង់ ........................................ ១០

២.៤. ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ឆ្នាំ២០១២) ........................................ ១០

២.៤. បទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ ........................................ ១០

**៣. អនុសញ្ញាអង្គការអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន និង សន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ** ........................................ ១២

៣.១. អនុសញ្ញាអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន ........................................ ១២

៣.២. អនុសញ្ញាអន្តរជាតិការពារសិទ្ធស្ត្រីដែលបានផ្តល់សច្ចាប័ន ........................................ ១៣

**៤. ច្បាប់ និងលិខិតបទដ្ឋានស្តីពីសុវត្ថិភាព និងសុខភាពការងារដែលចេញដោយក្រសួងពាក់ព័ន្ធ** .. ១៤

៤.១. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ ........................................ ១៤

៤.២. ក្រសួងរ៉ែ និងថាមពល ........................................ ១៤

៤.៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........................................ ១៤

៤.៤. ក្រសួងពាណិជ្ជកម្ម ........................................ ១៥

៤.៥. ក្រសួងសុខាភិបាល ........................................................ ១៥

៤.៦. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ........................................................ ១៦

៤.៧. ក្រសួងបរិស្ថាន ........................................................ ១៧

៤.៨. ក្រសួងសាធារណការ និងដឹកជញ្ជូន ........................................................ ១៧

៤.៩. ក្រសួងមហាផ្ទៃ ........................................................ ១៧

**៥. ការរៀបចំគោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេសស្តីពី សុវត្ថិភាព និងសុខភាពការងារ.. ១៩**

**៦. ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ........................................................ ១៩**

**III. យន្តការក្នុងការរៀបចំគោលនយោបាយជាតិ និង បទដ្ឋានស្តីពី សុវត្ថិភាព និងសុខភាពការងារ ........................................................ ២០**

**១. គោលនយោបាយជាតិសុវត្ថិភាព និងសុខភាពការងារ ........................................................ ២០**

**២. កម្មវិធីជាតិស្តីពី សុវត្ថិភាព និងសុខភាពការងារ ........................................................ ២០**

**៣. យន្តការរៀបចំបទប្បញ្ញត្តិស្តីពី សុវត្ថិភាព និងសុខភាពការងារ ........................................................ ២១**

**៤. នាយកដ្ឋានពេទ្យការងារ ........................................................ ២២**

**៥. រចនាសម្ព័ន្ធជាតិត្រីភាគីស្តីពី សុវត្ថិភាព និងសុខភាពការងារ ........................................................ ២៣**

៥.១. គណៈកម្មករប្រឹក្សាការងារ ........................................................ ២៣

៥.២. គណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ ........................................................ ២៤

៥.៣. គណៈកម្មាធិការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និង គ្រឿងញៀននៅកន្លែងធ្វើការ ........................................................ ២៥

**៦. យន្តការសម្របសម្រួល និងសហការ ........................................................ ២៦**

៦.១. ថ្នាក់ជាតិ ........................................................ ២៦

៦.២. ថ្នាក់រោងចក្រ សហគ្រាស ........................................................ ២៨

**៧. ប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារ៖ មធ្យោបាយ និងឧបករណ៍ ........................................................ ២៨**

៧.១. យន្តការដើម្បីធានាការអនុលោមតាមច្បាប់ ........................................................ ២៨

៧.២. មជ្ឈមណ្ឌលព័ត៌មានសុវត្ថិភាព និងសុខភាពការងារ ........................................................ ៣៥

៧.៣. សេវាផ្នែកសុវត្ថិភាព និងសុខភាពការងារ ........................................................ ៣៦

៧.៤. ការអប់រំ និងការបណ្តុះបណ្តាលអំពីសុវត្ថិភាព និងសុខភាពការងារ ដោយរាជរដ្ឋាភិបាល...៣៧

៧.៥. ការបណ្តុះបណ្តាលសុវត្ថិភាព និងសុខភាពការងារ
រៀបចំដោយអង្គការនិយោជក និងអង្គការកម្មករនិយោជិត ........ ៤០

**៨. ប្រព័ន្ធសំណងគ្រោះថ្នាក់ការងារ និងជំងឺ** ........ ៤២

៨.១. យន្តការ និងការទទួលខុសត្រូវរបស់ស្ថាប័ន ........ ៤២

៨.២. វិសាលភាព ........ ៤២

៨.៣. បញ្ជីគ្រោះថ្នាក់ការងារ និងរបួស ........ ៤៣

៨.៤. ជំងឺវិជ្ជាជីវៈ ........ ៤៨

៨.៥. ការដួលសន្លប់ ........ ៤៨

**IV. ស្ថានភាពទូទៅនៃធនធានមនុស្សក្នុងសកម្មភាព
សុវត្ថិភាព និងសុខភាពការងារ** ........ ៥១

**១. អ្នកផ្តល់សេវាសុវត្ថិភាព និងសុខភាពការងារ** ........ ៥១

**២. គោលនយោបាយ និងកម្មវិធីរបស់អង្គការនិយោជក និងអង្គការកម្មករនិយោជិត** ........ ៥៣

២.១. អង្គការនិយោជក ........ ៥៣

២.២. អង្គការកម្មករនិយោជិត ........ ៥៤

**៣. សកម្មភាពជាទៀងទាត់ និងបន្តពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ** ........ ៥៤

៣.១. ការគាំទ្រដល់រោងចក្រ សហគ្រាសធុនតូច មធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ៥៤

៣.២. ការអប់រំ ការលើកកម្ពស់ ការយល់ដឹង និងសកម្មភាពផ្សព្វផ្សាយអប់រំ ........ ៥៥

**ឧបសម្ព័ន្ធទី១៖ បទប្បញ្ញត្តិពាក់ព័ន្ធនានាដែលមានជាធរមានពីមុនមកមាន
នៅក្នុងក្របខណ្ឌព័ត៌មានជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ
បោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០១១** ........ ៥៩

**ឧបសម្ព័ន្ធទី២៖ អង្គការលេខរបស់ក្រសួងការងារ និង
បណ្តុះបណ្តាលវិជ្ជាជីវៈ** ........ ៦១

**ឧបសម្ព័ន្ធទី៣៖ ទិន្នន័យស្តីពីគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ** ........ ៦២

**ឧបសម្ព័ន្ធទី៤៖ គម្រោងកិច្ចសហប្រតិបត្តិការដែលគាំទ្រការអនុវត្តការងារ
ស្តីពីសុវត្ថិភាព និងសុខភាពការងារ** ........ ៦៤

**ឧបសម្ព័ន្ធទី៥៖ ស្ថានភាពនៃមជ្ឈមណ្ឌលសហជីពជាតិ**
**នៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៥** ............................................. ៦៦

**ឧបសម្ព័ន្ធទី៦៖ ស្ថានភាពសហជីពមូលដ្ឋាននៅក្នុង**
**ប្រទេសកម្ពុជា ឆ្នាំ២០១៥** ......................................................... ៦៧

**ឯកសារយោង** .......................................................................................... ៧០

# អារម្ភកថា

ការអនុវត្តវិធានការនានាប្រកបដោយប្រសិទ្ធភាព សម្រាប់ការពារគ្រោះថ្នាក់ការងារ និងជំងឺនៅគ្រប់កន្លែងធ្វើការ គឺជាផ្នែកមួយនៃធាតុចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេស។

កម្រងព័ត៌មានជាតិលើកទី២ ស្តីពីសុវត្ថិភាព និងសុខភាពការងារ សម្រាប់ប្រទេសកម្ពុជារួមបញ្ចូលព័ត៌មានថ្មីៗ និងអាចរកបានស្តីពី រចនាសម្ព័ន្ធមូលដ្ឋាននៃសុវត្ថិភាព និងសុខភាពការងារ (OSH) ច្បាប់ ការអនុវត្តច្បាប់ ប្រព័ន្ធសំណងគ្រោះថ្នាក់ការងារ ស្ថិតិ និងសកម្មភាពផ្សព្វផ្សាយស្តីពីសុវត្ថិភាព និងសុខភាពការងារ។ គោលបំណងនៃកម្រងព័ត៌មាននេះ គឺផ្តល់នូវមូលដ្ឋានសម្រាប់ពិនិត្យមើលភាពខ្លាំង និងបញ្ហាប្រឈមដែលកំពុងកើតមានបច្ចុប្បន្នលើផ្នែកសុវត្ថិភាព និងសុខភាពការងារនៅក្នុងប្រទេស និងជ្រើសរើសអាទិភាពសម្រាប់សកម្មភាពសុវត្ថិភាព និងសុខភាពការងារនាពេលអនាគត។

កម្រងព័ត៌មាននេះ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ (ILO) និងការផ្តល់មូលនិធិដោយគម្រោង "លើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា" នៃកម្មវិធីពហុភាគីរបស់ជប៉ុន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលខុសត្រូវក្នុងការបង្កើតកម្រងព័ត៌មាននេះ ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មការត្រីភាគី។

ចាប់តាំងពីការបង្កើតកម្រងព័ត៌មានជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារលើកទី១ ដំបូងគេដែលត្រូវបានគេស្គាល់ថាជា ទិដ្ឋភាពទូទៅនៃសុវត្ថិភាព និងសុខភាពការងារ នៃប្រទេសកម្ពុជា លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ នៅកម្ពុជាមានការផ្លាស់ប្តូរយ៉ាងខ្លាំង។ ដោយមានការសហការជាមួយអង្គការនិយោជក អង្គការកម្មករនិយោជិត អង្គការក្រៅរដ្ឋាភិបាល និងវិទ្យាស្ថានអន្តរជាតិដទៃទៀត រាជរដ្ឋាភិបាល បានអនុវត្តសកម្មភាព និងកម្មវិធីផ្សេងៗឆ្ពោះទៅរកការបង្កើតវប្បធម៌សុវត្ថិភាព និងសុខភាពការងារ តាមរយៈការផ្តួចផ្តើមជួយខ្លួនឯងដោយកម្មករនិយោជិត និងនិយោជក។ នៅក្នុងដំណើរការនៃការរៀបចំកម្រងព័ត៌មាននេះ រាជរដ្ឋាភិបាលបានពិនិត្យមើលឡើងវិញនូវស្ថានភាព សុវត្ថិភាព និងសុខភាពការងារ រួមមាន គោលនយោបាយ ប្រព័ន្ធ និងបណ្តាញក្នុងចំណោមអ្នកពាក់ព័ន្ធនឹងផ្នែកសុវត្ថិភាព និងសុខភាពការងារ។ ដោយផ្អែកលើកម្រងព័ត៌មាននេះ រាជរដ្ឋាភិបាលបានកំណត់សកម្មភាពអាទិភាព និងគោលដៅច្បាស់លាស់ ស្របតាមយុទ្ធសាស្រ្តដែលបានកំណត់នៅក្នុងគោលនយោបាយជាតិ ស្តីពីសុវត្ថិភាព និងសុខភាពការងារ។

កម្រងព័ត៌មានជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារនេះ បានចែងនូវផ្នែកសំខាន់ៗមានដូចជា៖

១- ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានពាក់ព័ន្ធស្តីពីសុវត្ថិភាព និងសុខភាពការងារ

២- បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសុខភាពការងារ

៣- គោលនយោបាយជាតិ និងយន្តការកំណត់ស្តង់ដារជាតិសុវត្ថិភាព និងសុខភាពការងារ

៤- យន្តការសម្របសម្រួល និងសហប្រតិបត្តិការ

៥- ការរៀបចំប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ៖ មធ្យោបាយ និងឧបករណ៍

៦- គោលនយោបាយ និងកម្មវិធីរបស់អង្គការនិយោជក និងអង្គការកម្មករនិយោជិត

៧- សកម្មភាពទៀងទាត់ និងកំពុងបន្តទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណដោយស្មោះជូនដល់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ អង្គការនិយោជក អង្គការកម្មករនិយោជិត ជាពិសេសសូមអរគុណដល់រាជរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុន តាមរយៈអង្គការអន្តរជាតិខាងការងារ ដែលបានចូលរួមយ៉ាងសកម្ម ជួយឧបត្ថម្ភគាំទ្រ ដល់ដំណើរការរៀបចំកម្រងព័ត៌មានជាតិលើកទី២ នេះឡើងប្រកបដោយជោគជ័យ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ[illegible]ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមថ្លែងអំណរគុណដល់ក្រុមការងារទាំងអស់ដែលបានខិតខំប្រឹងប្រែង និងផ្តល់ជំនាញបច្ចេកទេសក្នុងការប្រមូលទិន្នន័យ ជាពិសេសចំពោះរាជរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុនតាមរយៈអង្គការអន្តរជាតិខាងការងារ ដែលជួយឧបត្ថម្ភគាំទ្រដល់ដំណើរការរៀបចំកម្រងព័ត៌មានជាតិលើកទី២នេះ។ ជាមួយគ្នានេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមថ្លែងអំណរគុណដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការនិយោជក និងអង្គការកម្មករនិយោជិតទាំងអស់សម្រាប់ការសហការក្នុងការបំពេញកម្រងសំណួរ និងការផ្តល់នូវព័ត៌មាន ស្ថិតិ ស្តីពីសុវត្ថិភាព និងសុខភាពការងារនានា។ ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមថ្លែងអំណរគុណ ដល់សមាជិកក្រុមការងារខាងក្រោមចំពោះការដឹកនាំ និងការណែនាំផ្នែកបច្ចេកទេសដើម្បីរៀបចំ និងចងក្រងឯកសារនេះ៖

| | | |
|---|---|---|
| ១- ឯកឧត្តមវេជ្ជ. | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខការងារក្នុងវិស័យសំណង់ |
| ២- លោកជំទាវ | **ជា សុខនី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់ |
| ៣- លោកជំទាវ | **ម៉ៅ ធីតា** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៤- ឯកឧត្តមទន្ត. | **ឡេង តុង** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៥- ឯកឧត្តមវេជ្ជ. | **យី កន្និដ្ឋា** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាននាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៦- លោកវេជ្ជ. | **ខាន់ គុណា** | អនុប្រធាននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៧- លោកស្រីវេជ្ជ. | **ពេជ្រ ស្លាសិរី** | អនុប្រធាននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៨- លោក | **ភូង ម៉ុនធឿន** | អនុប្រធាននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៩- លោកស្រី | **គង់ សត្យា** | ប្រធានការិយាល័យអនាម័យការងារ |
| ១០-កញ្ញាវេជ្ជ. | **ស្តុន រដ្ឋា** | ប្រធានការិយាល័យស្ថិតិ និងទំនាក់ទំនងខាងក្រៅ |
| ១១- លោក | **ថៃ ហេងដា** | ប្រធានការិយាល័យឯកសារសុខភាពការងារ |

១២- លោកវេជ្ជ. **យុត សុភារ៉ា** ប្រធានការិយាល័យអាស៊ានអូស្ហណេត

១៣- លោក **ហ៊ាង លីនដា** អនុប្រធានការិយាល័យរដ្ឋបាល និងគណនេយ្យ

១៤- លោក **ចាន់ សំរិទ្ធ** អនុប្រធានការិយាល័យស្ថិតិ និងទំនាក់ទំនងខាងក្រៅ

១៥- លោក **សុខ វណ្ណៈ** អនុប្រធានការិយាល័យបច្ចេកទេស និងសន្តិសុខការងារ

១៦- លោក **តាន់ ហុកស្រេង** អនុប្រធានការិយាល័យឯកសារសុខភាពការងារ

១៧- លោក **ទិតហេង សាមុតស៊ីបូ** អនុប្រធានការិយាល័យបច្ចេកទេស និងសន្តិសុខការងារ

**ទីប្រឹក្សា និងមន្ត្រីគម្រោងផ្តល់ប្រឹក្សាបច្ចេកទេសលើឯកសារនេះ៖**

- លោក **ហ្សូ ស៊ូដូ** អ្នកគ្រប់គ្រងគម្រោង ILO/Japan OSH Project
- កញ្ញាវេជ្ជ. **យូមី សាណូ** ទីប្រឹក្សាបច្ចេកទេសគម្រោង ILO/Japan OSH Project
- លោក **ហ្វ្រង់ស៊ីស្កូ សានតូស អូកូណូ** ជំនាញការសុវត្ថិភាព និងសុខភាពការងារ ILO/Japan OSH Project
- លោក **ជុងហូ ឆេ** អ្នកឯកទេសសុវត្ថិភាព និងសុខភាពការងារ ILO/Japan OSH Project
- លោកស្រី **ប៉ោ ជួង** មន្ត្រីសម្របសម្រួលគម្រោង ILO/Japan OSH Project
- លោក **ជុន ម៉ូរ៉ា** ទីប្រឹក្សាបច្ចេកទេសគម្រោង ILO/Japan OSH Project

# អក្សរកាត់

| | |
|---|---|
| APHEDA | : អង្គការប្រជាជនអូស្ត្រាលីសម្រាប់សុខភាព ការអប់រំ និងការអភិវឌ្ឍ |
| ASEAN | : សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEAN-OSHNET | : បណ្តាញសុវត្ថិភាព និងសុខភាពការងារនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BWTUC | : សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា |
| CAID | : សមាគមកម្ពុជាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| CAMFEBA | : សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CCU | : សហព័ន្ធសហជីពកម្ពុជា |
| CEDAW | : អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CFSWF | : សហព័ន្ធកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា |
| CLOWBUF | : សហព័ន្ធកម្មករកម្ពុជា និងសហព័ន្ធសហជីព |
| CNAPWG | : ក្រុមការងារកសាងកម្រងព័ត៌មានជាតិស្តីពីអាបេស្តូសនៅកម្ពុជា |
| CUF | : សហព័ន្ធសហជីពកម្ពុជា |
| DOSH | : នាយកដ្ឋានពេទ្យការងារ |
| DoLI | : នាយកដ្ឋានអធិការកិច្ចការងារ |
| GHS | : ប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី |
| GMAC | : សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ILO | : អង្គការអន្តរជាតិខាងការងារ |
| JICA | : ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KOSHA | : ទីភ្នាក់ងារសុវត្ថិភាព និងសុខភាពការងារកូរ៉េ |
| MLVT | : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| SMEs | : សហគ្រាសធុនតូច និងមធ្យម |
| NSSF | : បេឡាជាតិសន្តិសុខសង្គម |
| NGO | : អង្គការមិនមែនរដ្ឋាភិបាល |
| OSH | : សុវត្ថិភាព និងសុខភាពការងារ |
| OSHMS | : ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ |
| PAB | : ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង |
| PAD | : សមាគមប្រជាជនដើម្បីការអភិវឌ្ឍ |
| PDCA | : វដ្តធ្វើផែនការ-អនុវត្ត-ពិនិត្យឡើងវិញ-ធ្វើសកម្មភាព |
| PTCs | : គណៈកម្មាធិការបច្ចេកទេសគម្រោង |

| | |
|---|---|
| RGC | : រាជរដ្ឋាភិបាលកម្ពុជា |
| TCC | : គណៈកម្មការសម្របសម្រួលត្រីភាគី |
| TPWFWI | : ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមបណ្តាសហគ្រាសគ្រឹះស្ថាន នៃបេឡាជាតិសន្តិសុខសង្គម |
| WHO | : អង្គការសុខភាពពិភពលោក |
| WIND | : ការកែលម្អរបៀបធ្វើការ និងអភិវឌ្ឍភូមិដ្ឋាន |
| WISCON | : ការកែលម្អរបៀបធ្វើការនៅក្នុងការដ្ឋានសំណង់ខ្នាតតូច |
| WISE | : ការកែលម្អរបៀបធ្វើការនៅក្នុងសហគ្រាសខ្នាតតូច |
| WISH | : ការកែលម្អការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារតាមផ្ទះ |

## I. សាវតា

### ១. ព័ត៌មានភូមិសាស្ត្រនិងប្រជាសាស្ត្រ

ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងមានព្រំប្រទល់ជាប់ប្រទេសវៀតណាមនៅភាគខាងកើត និងខាងត្បូង ជាប់ប្រទេសឡាវនៅភាគឦសាន ជាប់ប្រទេសថៃនៅភាគខាងលិច និងពាយព្យ និងជាប់ឈូងសមុទ្រថៃនៅភាគនិរតី។ យោងតាមអត្រាជំរឿនជាតិឆ្នាំ២០១៩ ប្រទេសកម្ពុជាមានចំនួន ៣.៣៤១.៧៧០គ្រួសារ ដែលមានប្រជាជនចំនួន ១៥.២៨៨.៤៨៩នាក់។ ក្នុងចំណោមប្រជាជនសរុបនេះ បុរសមានចំនួន ៧.៤១៨.៥៧៧នាក់ (៤៨,៥%) និងស្ត្រីមានចំនួន ៧.៨៦៩.៩១២នាក់ (៥១,៥%)។ ក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១៩ ចំនួនប្រជាជនបានកើនឡើងចំនួន ១.៨៩២.៨០៧នាក់ ស្មើនឹង ១៤,១%។ ចំនួនប្រជាជនសរុបនេះ មិនរាប់បញ្ចូលពលករចំណាកស្រុកកម្ពុជាដែលរស់នៅក្រៅប្រទេស ភាគច្រើនធ្វើការនៅតាមបណ្តាប្រទេសអាស៊ី និងប្រទេសដទៃទៀត ដូចជាប្រទេសថៃចំនួន ១.១៤៦.៦៨៥នាក់ ម៉ាឡេស៊ីចំនួន ៣០.១១៣នាក់ សាធារណរដ្ឋកូរ៉េចំនួន ៤៩.០៩៩នាក់ សឹង្ហបុរីចំនួន ៨៣១នាក់ ជប៉ុនចំនួន ៩.១៩៥នាក់ ហុងកុងចំនួន ៥៤នាក់ និងអារ៉ាប់ប៊ីសាអូឌីតចំនួន ១៦នាក់ (យោងតាមជំរឿនជាតិឆ្នាំ២០១៩)។

**រូបភាពទី ១៖ កម្លាំងពលកម្មទាក់ទងនឹងអាយុប្រជាជនដែលអាចធ្វើការ ( ១៥ - ៦៤ ឆ្នាំ ) ឆ្នាំ២០១៧**




*យោង៖ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០១៧ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*

## ២ .អំពីស្ថានភាពស្តីពីសុវត្ថិភាព និងសុខភាពការងារ

ប្រទេសកម្ពុជា បានកែប្រែស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួនពីប្រទេសដែលមានប្រាក់ចំណូលទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមមួយ ដែលបច្ចុប្បន្នកំពុងជំរុញឆ្ពោះទៅរកប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានគោលដៅចុងក្រោយក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ យោងតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤ នៃរដ្ឋសភានីតិកាលទី៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលឆ្នាំ២០១៩-២០២៣។ ការអភិវឌ្ឍតាមយុទ្ធសាស្ត្រនេះ បានជួយឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់នៅក្នុងវិស័យទាំងនេះ។

សុវត្ថិភាព និងសុខភាពការងារ គឺជាផ្នែកអាទិភាពមួយផ្សេងទៀតសម្រាប់រាជរដ្ឋាភិបាល។ វាជាការចាំបាច់ដែលត្រូវពង្រឹងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅតាមកន្លែងធ្វើការ ដើម្បីការពារកម្លាំងពលកម្មរបស់ប្រទេសទាំងនៅកម្រិតជាតិ និងកម្រិតរោងចក្រ សហគ្រាស។ សុវត្ថិភាព និងសុខភាពការងារ គឺជាបញ្ហាសំខាន់បំផុតនៅទូទាំងពិភពលោក ដោយទាមទារនូវវិធានការណ៍ឆ្លើយតបបន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធដូចជា រាជរដ្ឋាភិបាល អង្គការនិយោជក និងអង្គការកម្មករនិយោជិត អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។ នៅពេលដែលឧស្សាហកម្ម និងបច្ចេកវិទ្យាកំពុងអភិវឌ្ឍសុខភាព និងសុវត្ថិភាពការងារ ត្រូវបានយកមកពិចារណាជាអាទិភាពដ៏សំខាន់មួយក្នុងការគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យការងារដែលអាចកើតឡើងនៅគ្រប់កន្លែងធ្វើការ។

សុវត្ថិភាព និងសុខភាពការងារ ត្រូវបានកំណត់ថាជាផ្នែកដ៏សំខាន់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលឆ្នាំ២០១៩-២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកដ្ឋានពេទ្យការងារ គឺជាអង្គភាពជំនាញដ៏សំខាន់មួយនៅក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុវត្ត និងដោះស្រាយបញ្ហាសុវត្ថិភាព និងសុខភាពការងារនៅថ្នាក់ជាតិ និងសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រខាងលើ។ នាយកដ្ឋានពេទ្យការងារ បានរៀបចំបង្កើតផែនការមេលើកទី២ ស្តីពីសុវត្ថិភាព និងសុខភាពការងារឆ្នាំ ២០១៨-២០២២ ដែលជាការបង្ហាញផ្លូវដល់ការអភិវឌ្ឍវិធីសាស្ត្រជាតិដែលគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ។

អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ ជាពិសេសអនុសញ្ញាលេខ១៥៥ (ស្តីពី សុវត្ថិភាព និងសុខភាពការងារ ឆ្នាំ១៩៨១) អនុសញ្ញាលេខ១៨៧ (ស្តីពីក្របខ័ណ្ឌផ្សព្វផ្សាយស្តីពី សុវត្ថិភាព និងសុខភាពការងារ ឆ្នាំ២០០៦) និងគោលការណ៍ណែនាំ ILO-OSH ២០០១ (ស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ) ត្រូវបានប្រើប្រាស់ជាឯកសារយោងនៅក្នុងការរៀបចំផែនការមេ។ យន្តការពិគ្រោះយោបល់ត្រីភាគីត្រូវបានបង្កើតឡើង ដើម្បីពង្រឹងគោលនយោបាយជាតិ និងក្របខ័ណ្ឌច្បាប់។ កិច្ចប្រជុំ

របស់គណៈកម្មការប្រឹក្សាការងារ និងគណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ ត្រូវបានរៀបចំឡើងសម្រាប់គោលបំណងនេះ។

## II. ក្របខ័ណ្ឌច្បាប់ និងលិខិតតូបករណ៍ពាក់ព័ន្ធស្តីពីសុវត្ថិភាព និងសុខភាពការងារ

### ១. ឯកសារយោងនៅក្នុងរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តដោយសន្និបាតរដ្ឋធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ក្នុងសម័យប្រជុំលើកទី២របស់ខ្លួន។ ជំពូកទី៣ មាត្រា៣៥ ៣៦ ៣៨ ៤៦ ៤៧ និង មាត្រា ៤៨ ពិពណ៌នាអំពីលក្ខខណ្ឌទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ។

### ២. ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ

#### ២ .១. ច្បាប់ស្តីពីការងារ

ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ ក្នុងសម័យប្រជុំលើកទី៧ នីតិកាលទី១ និងត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។ មាត្រាដែលទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារមានចែងក្នុងជំពូកទី៨ និងមានលម្អិតដូចខាងក្រោម៖

- អនាម័យ និងសន្តិសុខនៃកម្មករនិយោជិត មាត្រា ២២៨ ដល់ ២៤៧
- ដែនអនុវត្ត មាត្រា ២២៨
- បទប្បញ្ញត្តិទូទៅ មាត្រា ២២៩ ដល់ មាត្រា២៣២
- ការត្រួតពិនិត្យ មាត្រា ២៣៣ ដល់ មាត្រា២៣៧
- សេវាពេទ្យការងារ មាត្រា ២៣៨ ដល់ មាត្រា២៤៧

#### ២.២. ច្បាប់ ស្តីពីរបបសន្តិសុខសង្គម

ច្បាប់ស្តីពីរបបសន្តិសុខសង្គម ពង្រីកបេឡាជាតិសន្តិសុខសង្គម ដើម្បីផ្តល់សំណាញ់សុវត្ថិភាពហិរញ្ញវត្ថុដល់មន្ត្រីរាជការ និងអ្នកដែលនៅក្នុងវិស័យឯកជន និងក្រៅប្រព័ន្ធ។ ច្បាប់នេះ មាន១១ជំពូក និង១០៧មាត្រា ត្រូវបានអនុម័តនៅទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ រដ្ឋសភាពិភាក្សា និងអនុម័តនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ និងត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ច្បាប់នេះមានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឱ្យមានសមធម៌សង្គម សាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែល

ស្ថិតនៅក្រោមបទប្បញ្ញតិនៃច្បាប់ស្ដីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស នាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

### ២.៣. ច្បាប់ ស្ដីពីសំណង់

ច្បាប់ស្ដីពីសំណង់ ត្រូវបានបង្កើតឡើងតាមរយៈការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងនោះរួមមានក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈផងដែរ។ ច្បាប់នេះមាន ២២ជំពូក និង១១១មាត្រា។ ទោះបីជាមិនមានជំពូក ឬមាត្រាជាក់លាក់ណាមួយដែលទាក់ទងនឹងបញ្ហាសុវត្ថិភាព និងសុខភាពការងារនៅក្នុងការសាងសង់ក៏ដោយ ក៏មានការយកចិត្តទុកដាក់ជាទូទៅលើសុវត្ថិភាពសំណង់ ហើយច្បាប់នេះរួមបញ្ចូលទាំងការដោះស្រាយហានិភ័យដែលអាចបង្កឱ្យមានគ្រោះថ្នាក់នៅក្នុងការដ្ឋានសំណង់។

ច្បាប់នេះត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ និងត្រូវបានព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពី ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។ ច្បាប់នេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។

### ២.៤. ច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ឆ្នាំ២០១២)

ច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មត្រូវបានដាក់ឱ្យប្រើនៅឆ្នាំ២០១២។

### ២.៥. បទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ

បទប្បញ្ញត្តិដែលមានចែងក្នុង "កម្រងព័ត៌មានជាតិស្ដីពី សុវត្ថិភាព និងសុខភាពការងារ នៃព្រះរាជាណាចក្រកម្ពុជា" ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១១ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១។ ការសម្របសម្រួលគម្រោង ការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ក្នុងដំណើរការចងក្រង និងបញ្ចូលបទប្បញ្ញត្តិទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ និងបង្កើតក្របខ័ណ្ឌច្បាប់មួយដែលស្របតាមស្តង់ដារអន្តរជាតិ។

#### ២.៥.១. អនុក្រឹត្យ

អនុក្រឹត្យលេខ ១២៣ អនក្របក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីក្នុងការផ្ដល់ការអនុញ្ញាតដល់ពលករបរទេសដែលមិនមែនជាជនចំណាកស្រុកឱ្យចូល ចាកចេញ ធ្វើការ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២.៩.២. ប្រកាស

❖ ប្រកាសស្តីពីសុវត្ថិភាព និងសុខភាពការងារ

- ប្រកាសលេខ១៧៦ ក.ប/ប្រ.ក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេស សន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព
- ប្រកាសលេខ១៩៤ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មរាន្ត។

❖ ប្រកាស ស្តីពីពលកម្មកុមារ

- ប្រកាសលេខ២៤០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីពលកម្មកុមារក្នុងកសិដ្ឋានដំឡូងមី
- ប្រកាសលេខ២៤១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារក្នុងការងារនេសាទតាមដងទន្លេ
- ប្រកាសលេខ២៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីពលកម្មកុមារក្នុងវិស័យកសិកម្ម
- ប្រកាសលេខ២៤៣ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីលក្ខខណ្ឌការងារកុមារក្នុងកសិដ្ឋានថ្នាំជក់
- ប្រកាសលេខ៤៦៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីនីតិវិធីជ្រើសរើសពលកររវ័យក្មេងសម្រាប់សហគ្រាសទាំងអស់។

❖ ប្រកាស ស្តីពីប្រាក់ឈ្នួល

- ប្រកាសលេខ៣០៣/២០ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២១
- ប្រកាសលេខ៣៨៩/១៩ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០
- ប្រកាសលេខ៤៦៥ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩
- ប្រកាសលេខ៣៩៦ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសម្រាប់ឆ្នាំ២០១៨

- ប្រកាសលេខ៤១៤ ចុះថ្ងៃទី២៩ ខែកញ្ញាឆ្នាំ២០១៦ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសម្រាប់ឆ្នាំ ២០១៧
- ប្រកាសលេខ៤០៩/១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសម្រាប់ឆ្នាំ ២០១៦
- ប្រកាសលេខ២៨៣ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសម្រាប់ឆ្នាំ ២០១៥
- ប្រកាសលេខ៣១៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិត នៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសម្រាប់ឆ្នាំ ២០១៤។

❖ ប្រកាស ស្តីពីមុខរបរ និងការងារ

- ប្រកាសលេខ១៩៧ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីសៀវភៅការងារសម្រាប់ពលករខ្មែរ
- ប្រកាសលេខ១៩៦ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីការងាររបស់ពលករបរទេស
- ប្រកាសលេខ១៩៧-៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីកាតការងារនិងសៀវភៅ ការងារសម្រាប់ពលករបរទេស
- ប្រកាសលេខ៧១៩ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រកាសអន្តរក្រសួង (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ) ស្តីពីការពង្រឹងអធិការកិច្ចការងារពលករ បរទេសនៅព្រះរាជាណាចក្រកម្ពុជា។

## ៣ . អនុសញ្ញាអង្គការអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន និងសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ

### ៣. ១. អនុសញ្ញាអង្គការអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន

❖ អនុសញ្ញាមូលដ្ឋាន/គោល

- អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ (បានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៦៩)
- អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពសមាគម និងការការពារសិទ្ធិក្នុងការរៀបចំ (បាន ផ្តល់សច្ចាប័ននៅឆ្នាំ ១៩៩៩)

- អនុសញ្ញាលេខ៩៨ ស្តីពីសិទ្ធិក្នុងការរៀបចំ និងចរចាសមូហភាព (បានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៩៩)
- អនុសញ្ញាលេខ១០០ ស្តីពីការផ្តល់សំណងស្មើគ្នា (បានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩៩)
- អនុសញ្ញាលេខ១០៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ (បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩)
- អនុសញ្ញាលេខ១១១ ស្តីពីការរើសអើងការងារ និងមុខរបរ (បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩)
- អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមា (បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩)
- អនុសញ្ញាលេខ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (បានផ្តល់សច្ចាប័ននៅឆ្នាំ២០០៦)។

❖ អនុសញ្ញាអភិបាលកិច្ច (អាទិភាព)

- អនុសញ្ញាលេខ១២២ ស្តីពីអនុសញ្ញាគោលនយោបាយការងារ (ផ្តល់សច្ចាប័ននៅ ឆ្នាំ១៩៧១)។

❖ អនុសញ្ញាបច្ចេកទេស

- អនុសញ្ញាលេខ៦ ស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង (ឧស្សាហកម្ម) (បានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៦៩)
- អនុសញ្ញាលេខ៤ ស្តីពីការងារពេលយប់ (ស្ត្រី) (បានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៦៩)។

❖ អនុសញ្ញាដែលបាននិរាករណ៍ ដោយសេចក្តីសម្រេចរបស់សន្និសីទការងារអន្តរជាតិ-ILC នៅសម័យប្រជុំលើកទី ១០៦ (ឆ្នាំ ២០១៧)៖

- អនុសញ្ញាលេខ១៣ ស្តីពីសំណពណ៌ស (បានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៦៩)
- អនុសញ្ញាលេខ១៥០ ស្តីពីអនុសញ្ញារដ្ឋបាលការងារឆ្នាំ១៩៧៨ (បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩)។

## ៣.២. អនុសញ្ញាអន្តរជាតិការពារសិទ្ធិស្ត្រីដែលបានផ្តល់សច្ចាប័ន

អនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី របស់អង្គការសហប្រជាជាតិ ត្រូវបានអនុម័តដោយដំណោះស្រាយលេខ ៣៤/១៨០ នៃមហាសន្និបាត នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ និងចូលជាធរមានចាប់ពីថ្ងៃទី៣

ខែកញ្ញា ឆ្នាំ១៩៨១។ ប្រទេសកម្ពុជា បានចុះហត្ថលេខាផ្តល់សច្ចាប័នលើអនុសញ្ញាស៊ីដនេះ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។

**៤. ច្បាប់ និងលិខិតបទដ្ឋានស្តីពីសុវត្ថិភាព និងសុខភាពការងារដែលចេញដោយក្រសួងពាក់ព័ន្ធ**

ក្រៅពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្រសួងផ្សេងៗទៀតបានចេញលិខិតបទដ្ឋានដែលទាក់ទងនឹងផ្នែកសុវត្ថិភាព និងសុខភាពការងារ។

**៤.១. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្មលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ និងច្បាប់វិសោធនកម្ម ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើនាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩
- ប្រកាសលេខ១៥២ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលមានហានិភ័យ។

**៤.២. ក្រសួងរ៉ែ និងថាមពល**

- ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨
- សៀវភៅណែនាំស្តីពីសុវត្ថិភាពការដ្ឋានរ៉ែ ចុះនៅខែកុម្ភៈ ឆ្នាំ២០១៧
- សារាចរលេខ០១៤០ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយបូមប្រេង និងឧស្ម័នឥន្ធនៈ។

**៤.៣ . ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- អនុក្រឹត្យលេខ១៦ អនក្រប ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពី ការគ្រប់គ្រងអនាម័យសត្វនិងផលិតផលពីសត្វ មានចំនួន ៩ជំពូក និង៣៤មាត្រា។ អនុក្រឹត្យនេះមានគោលបំណងត្រួតពិនិត្យអនាម័យសត្វ និងផលិតផលដែលមានប្រភពចេញពីសត្វដើម្បីការពារការចម្លងជំងឺ ពីសត្វទៅសត្វ និងពីសត្វទៅសាធារណជនទូទៅ
- អនុក្រឹត្យលេខ៦៩ អនក្របក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពី ការធ្វើឱ្យមានស្តង់ដារ និងការគ្រប់គ្រងសម្ភារកសិកម្ម

- អនុក្រឹត្យលេខ១០៨ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងកន្លែងសត្តឃាត និងអនាម័យសាច់សត្វ និងផលិតផលសត្វ
- អនុក្រឹត្យលេខ២៦ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងភ្នាក់ងារសុខភាពសត្វក្នុងភូមិ
- អនុក្រឹត្យលេខ១៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងអនាម័យរុក្ខសាស្ត្រ
- អនុក្រឹត្យស្តីពីការហាមឃាត់ផលិតផល POP ចំនួន ១២ លើជីកសិកម្ម
- ប្រកាសលេខ១១៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីបញ្ជីជំងឺសត្វឆ្លង
- ប្រកាសលេខ៤៥៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការពង្រឹងវិធានការបង្ការសម្រាប់ជំងឺផ្តាសាយបក្សី
- ប្រកាសលេខ៣៣៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ និងផលិតផលកសិកម្ម
- សារាចរលេខ០២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការត្រួតពិនិត្យការនាំចូលសត្វរស់ និងផលិតផលស៊ុតនៅតាមព្រំដែន
- សារាចរលេខ៣៤៥ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការធ្វើឱ្យមានស្តង់ដារនិងការគ្រប់គ្រងសម្ភារកសិកម្ម
- គោលការណ៍ណែនាំ ស្តីពីការប្រើប្រាស់សារធាតុគីមីប្រកបដោយសុវត្ថិភាព ចេញក្នុងឆ្នាំ ២០០២
- សេចក្តីជូនដំណឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៤ ទាក់ទងនឹងត្រីពុល។

## ៤.៤. ក្រសួងពាណិជ្ជកម្ម

- អនុក្រឹត្យលេខ៤៧ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស។ គោលបំណងរបស់អនុក្រឹត្យនេះ គឺដើម្បីកំណត់វិធានទូទៅនៃអនាម័យរបស់ផលិតផលអាហាររបស់មនុស្ស រួមទាំងគ្រឹះស្ថានផលិត ឬកម្មករនិយោជិតដែលធ្វើការនៅទីនោះ។

## ៤.៥. ក្រសួងសុខាភិបាល

- គោលនយោបាយជាតិសម្រាប់សេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ឆ្នាំ២០០៩
- គោលនយោបាយជាតិការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព នៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០
- គោលនយោបាយជាតិការបង្ការ និងត្រួតពិនិត្យការចម្លងរោគ ខែមិថុនា ឆ្នាំ២០១៩

- ប្រកាសស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩
- មគ្គុទ្ទេសក៍ជាតិស្តីពីជីវសុវត្ថិភាពមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ឆ្នាំ២០១៦
- មគ្គុទ្ទេសក៍ជាតិស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព ឆ្នាំ២០១២
- សៀវភៅមគ្គុទេសក៍ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំសម្រាប់គ្រឹះស្ថានថែទាំសុខភាពសាធារណៈ និងឯកជន
- គោលការណ៍ណែនាំជាតិស្តីពី ការប្រើប្រាស់ឱសថប្រឆាំងមេរោគនៅក្នុងមូលដ្ឋានព្យាបាល និងថែទាំសុខភាព ខែកញ្ញា ឆ្នាំ២០១៩
- គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៧
- គោលការណ៍ណែនាំស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំ និងការគ្រប់គ្រងកាកសំណល់នៅក្នុង មន្ទីរពេទ្យ ចុះថ្ងៃ៣១ ខែមករា ឆ្នាំ២០០១
- កម្មវិធីសិក្សាស្តីអំពីសុវត្ថិភាពនៃការចាក់ថ្នាំសម្រាប់គ្រូបង្គោល ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៧
- នីតិវិធីប្រតិបត្តិស្តង់ដារស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគជំងឺកូវីដ-១៩ នៅ មូលដ្ឋានសុខាភិបាល និងកន្លែងថែទាំអ្នកជំងឺនៅកម្ពុជា ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។

## ៤.៦. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- អនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃ ការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រកាសលេខ០៣៣ ដនស/ប្រក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទ និងបរិបទ នៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្ត សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់
- ប្រកាសលេខ១៧៧ ដនស/ប្រក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទនិងនីតិវិធីនៃ ការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូល ជាធរមាន
- ប្រកាសទាក់ទងនឹងការ ពិន័យចំពោះការបំពានផ្សេងៗនៅក្នុងវិស័យសំណង់។

## ៤.៧. ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ស្តីពីការកែសម្រួល មាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥នៃ អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការ បំពុលទឹក
- អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យ លេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- អនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ស្តីពីការគ្រប់គ្រងលើការ ចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការបំពុលខ្យល់ និង ការត្រួតពិនិត្យសំឡេង
- អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង សំណល់រឹង
- អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងការ បំពុលទឹក។

## ៤.៨. ក្រសួងសាធារណការ និងដឹកជញ្ជូន

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (វិសោធនកម្មះ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧)
- អនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

## ៤..៩. ក្រសួងមហាផ្ទៃ

- ច្បាប់ស្តីពីការបង្ការ និងពន្លត់អគ្គិភ័យ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០២១។ ជំពូកទី១ស្តីពី បទប្បញ្ញត្តិទូទៅ មាត្រា៤ ត្រង់ចំណុចឃ្លាមួយ បញ្ជាក់ថា "ការបង្ការអគ្គិភ័យ សំដៅដល់ការអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បី ធានាសុវត្ថិភាព មិនឱ្យមានអគ្គិភ័យកើតឡើង"។ ជំពូកទី៣ ស្តីពីការបង្ការអគ្គិភ័យ មាត្រា ១៨ ត្រង់ចំណុចឃ្លាមួយបញ្ជាក់ថា "រាល់សំណង់ត្រូវធានាឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់ អគ្គិភ័យមុនដំណើរការសាងសង់"

- ច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី២៦ ខែសីហា ឆ្នាំ ១៩៩៤ ជំពូកទី៣ ស្តីពីជនបរទេសអន្តោប្រវេសន៍ មាត្រា១៨ ចែងថាៈ ការទទួលជនបរទេសឱ្យធ្វើការត្រូវអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យបណ្ណ័ការងាររបស់ជនបរទេសនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន គ្រឹះស្ថាននានា ដោយសហការជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។
- ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវា ដែលបានអនុម័តនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ជំពូកទី៣ ស្តីពីសិទ្ធិអ្នកប្រើ និងកាតព្វកិច្ច មាត្រា៣ ចែងថា ៖ ៉ផលិតករ និងសេវាករ មានកាតព្វកិច្ចបញ្ជាក់បង្ហាញជាភាសាខ្មែរលើផលិតផលទំនិញ និងសេវារបស់ខ្លួនអំពីធាតុផ្សំ វិធីប្រើប្រាស់ កាលបរិច្ឆេទផលិតផលរយៈពេលហួសកំណត់ប្រើប្រាស់ រួមទាំងគោលការណ៍ផ្សេងៗទៀត ដែលធានាបាននូវសុវត្ថិភាព និងសុខភាពអ្នកប្រើ មុននឹងផលិតផល ទំនិញ និងសេវានេះចូលក្នុងដំណើរការធ្វើពាណិជ្ជកម្ម»។ ជំពូកទី៦ ស្តីពីវិធានការទប់ស្កាត់ផលិតផលទំនិញ មាត្រា២២ ចែងថា ៉ចំពោះផលិតកម្មសហគ្គាករណ៍ ពាណិជ្ជកម្មនៃផលិតផលទំនិញ ឬសេវាដែលអាចបង្កឱ្យគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬអាចបង្កឱ្យមានគ្រោះថ្នាក់បន្ទាន់ចំពោះសុខភាព ឬសុវត្ថិភាពដល់អ្នកប្រើប្រាស់៉ ក្រសួងមានសមត្ថកិច្ចអាចចាត់វិធានការ បញ្ឈប់ជាស្ថាពរ ឬសម្រាប់រយៈពេលកំណត់មួយ បិទទ្វារគ្រឹះស្ថានផលិតជាបណ្តោះអាសន្ន ឬជាស្ថាពរ ក្នុងករណីចាំបាច់បន្ទាន់អាចធ្វើការឃាត់ទុកនៅនឹងកន្លែងរឹបអូស ឬបំផ្លាញចោលនូវផលិតផលទាំងនោះ
- អនុក្រឹត្យលេខ១៣១ អនក្រ.បក ស្តីពីលក្ខខណ្ឌ និងវិធានការនានា ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។ ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាត្រា៤ ៉លក្ខខណ្ឌ និងវិធាន សំដៅដល់លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ធានាសុវត្ថិភាពកុំឱ្យមានអគ្គិភ័យកើតមានឡើង៉។ ជំពូកទី៣ ស្តីពីលក្ខខណ្ឌ និងវិធានការបង្ការអគ្គិភ័យ មាត្រា៩ៈអ្នកគ្រប់គ្រងគោលដៅទីកន្លែងផលិតកែច្នៃ និង/ឬស្តុកទុកសារធាតុងាយឆេះ ឬផ្ទុះឆេះ ប្រភពភ្លើង និងប្រភពកំដៅត្រូវគោរពតាមលក្ខខណ្ឌ និងវិធានដូចខាងក្រោម ស្ថិតនៅឆ្ងាយពីទីប្រជុំជន មន្ទីរពេទ្យ សាលារៀន ផ្សារ រោងចក្រ សហគ្រាស និង/ឬអង្គភាពកងកម្លាំងប្រដាប់អាវុធទៅតាមទំហំនៃបរិមាណស្តុកទុក យ៉ាងតិចចំងាយ ១០០ម៉ែត្រ។ ជំពូកទី៤ ស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីនគរបាល និងសមត្ថកិច្ចពាក់ព័ន្ធពន្លត់អគ្គិភ័យ ត្រង់មាត្រា១៤ ត្រង់ចំណុចឃ្លាមួយបញ្ជាក់ថា ក្នុងករណីមានអគ្គិភ័យកើតឡើង មន្ត្រីនគរបាល និង/ឬ សមត្ថកិច្ចពាក់ព័ន្ធពន្លត់អគ្គិភ័យ ដឹកនាំបញ្ជាពន្លត់អគ្គិភ័យត្រូវ សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពផ្សេងៗទៀតជួយសង្គ្រោះអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិបន្ទាន់ដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈនៅក្នុង និងជុំវិញកន្លែងដែលអគ្គិភ័យកើតឡើង

- អនុក្រឹត្យលេខ ០៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។ ជំពូកទី២ ស្តីពីសមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ មាត្រា៥៖ ក្រសួងមហាផ្ទៃ មានសមត្ថកិច្ច៖ ត្រួតពិនិត្យប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យលើរាល់សំណង់ និងគោលដៅឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ត្រួតពិនិត្យឧបករណ៍ សម្ភារ បរិក្ខារសម្រាប់បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យស្របតាមបទដ្ឋានបច្ចេកទេស ត្រួតពិនិត្យទីតាំងស្តុក ដាក់លក់ឧបករណ៍ សម្ភារ បរិក្ខារបង្ការ និងពន្លត់អគ្គិភ័យ បញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចេញលិខិតផ្អាកសកម្មភាពបណ្តោះអាសន្នដល់ផ្នែកណាមួយនៃសំណង់ និងគោលដៅដែលខ្វះលក្ខខណ្ឌ និងវិធានការបង្ការ និងពន្លត់អគ្គិភ័យ
- ប្រកាសលេខ៦៣៨០ ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការប្រគល់សិទ្ធិត្រួតពិនិត្យសំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។

## ៥. ការរៀបចំគោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេស ស្តីពីសុវត្ថិភាព និងសុខភាពការងារ

- គោលការណ៍ប្រតិបត្តិស្តង់ដារស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាស តាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២
- កម្រងព័ត៌មានជាតិ ស្តីពីសារធាតុអាបេសស្តូសនៅកម្ពុជា របស់ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ
- គោលការណ៍ណែនាំ ស្តីពីការរៀបចំគិលានដ្ឋាននៅតាមសហគ្រាស គ្រឹះស្ថានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមការងារ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧
- អនុវត្តគោលការណ៍ណែនាំនៃច្បាប់ ស្តីពីការការពារ និងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅខែមីនា ឆ្នាំ២០០៥
- គោលការណ៍ណែនាំ ស្តីពីសុវត្ថិភាពសារធាតុគីមីនៅកន្លែងធ្វើការ។

## ៦. ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ

រាជរដ្ឋាភិបាល បានលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ តាមរយៈគោលការណ៍នៃវដ្តធ្វើផែនការ- អនុវត្ត-ពិនិត្យឡើងវិញ-ធ្វើសកម្មភាព (PDCA)។ រាជរដ្ឋាភិបាល ធ្វើការយកចិត្តទុកដាក់ដល់សហគ្រាសខ្នាតតូច និងមធ្យម តាមរយៈការអនុវត្តវដ្ត នៅកន្លែងធ្វើការ។ ការបណ្តុះបណ្តាលស្តីពី ការកែលម្អការងារនៅតាមសហគ្រាសខ្នាតតូច ការកែលម្អការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ ការដ្ឋានសំណង់ខ្នាតតូច គឺមានសារៈសំខាន់ក្នុងការអនុវត្តនៃការគ្រប់គ្រងផ្នែកសុវត្ថិភាព និងសុខភាពការងារ។ នាយកដ្ឋានពេទ្យការងារ បានរៀបចំផែនការមេលើកទី២ ស្តីពីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ២០១៨-២០២២ ដែលជាផែនទីចង្អុលទិសសម្រាប់ជួយគាំទ្រក្នុងការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាព

និងសុខភាពការងារ ដោយយោងតាមអនុសញ្ញាលេខ១៥៥ ស្ដីពីសុវត្ថិភាព និងសុខភាពការងារ និង អនុសញ្ញាលេខ១៨៧ ស្ដីពីការផ្សព្វផ្សាយសម្រាប់ការការពារសុវត្ថិភាព និងសុខភាពការងារ។

## III. យន្តការក្នុងការរៀបចំគោលនយោបាយជាតិ និងបទដ្ឋាន ស្ដីពីសុខភាព និង សុវត្ថិភាពការងារ

### ១. គោលនយោបាយជាតិសុវត្ថិភាព និងសុខភាពការងារ

គោលនយោបាយជាតិសុវត្ថិភាព និងសុខភាពការងារ រៀបចំដោយក្រសួងការងារ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈក្រោមការគាំទ្រថវិកា និងបច្ចេកទេសរបស់ គម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារជប៉ុន នៃអង្គការអន្តរជាតិខាងការងារ។

### ២. កម្មវិធីជាតិស្ដីពីសុវត្ថិភាព និងសុខភាពការងារ

កម្មវិធីជាតិស្ដីពីសុវត្ថិភាព និងសុខភាពការងារ រួមមាន “ផែនការមេលើកទី១ ស្ដីពីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ២០០៩-២០១៣” និង “ផែនការមេលើកទី២ ស្ដីពីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ២០១៨-២០២២” ដែលរៀបចំដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្រោមការគាំទ្រពីអង្គការអន្តរជាតិខាងការងារ បាននឹងកំពុងអនុវត្តដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារថ្នាក់ជាតិ និងថ្នាក់រោងចក្រ សហគ្រាស។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានអនុវត្តកម្មវិធី និងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនស្របតាមផែនការមេលើកទី២ ដែលមានដូចជា៖

#### *ទស្សនវិស័យ*

បង្កើត និងលើកកម្ពស់វប្បធម៌ការពារសុវត្ថិភាព និងសុខភាពការងារ នៅគ្រប់ទីកន្លែងធ្វើការទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

#### *បេសកកម្ម*

- បង្កើត និងអនុវត្តនូវគោលនយោបាយ បទដ្ឋាន និងក្របខ័ណ្ឌច្បាប់ស្ដីពីសុវត្ថិភាព និងសុខភាពការងារ ដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អង្គការវិជ្ជាជីវៈ ក្នុងការជំរុញសកម្មភាពផ្នែកសុវត្ថិភាព និងសុខភាពការងារ
- លើកកម្ពស់សមត្ថភាពមន្ត្រីអធិការការងារ និងអ្នកពាក់ព័ន្ធក្នុងវិស័យសុវត្ថិភាព និងសុខភាពការងារ
- លើកកម្ពស់គុណភាពសេវាសុវត្ថិភាព និងសុខភាពការងារ
- ផ្តល់ការការពារ និងលើកកម្ពស់ការយល់ដឹងផ្នែកសុវត្ថិភាព និងសុខភាពការងារឱ្យបានទូលំទូលាយដល់និយោជក និងកម្មករនិយោជិតទាំងអស់
- ជំរុញឱ្យមានប្រព័ន្ធគ្រប់គ្រងសុខភាពនិងសុវត្ថិភាពការងារនៅគ្រប់កន្លែងធ្វើការ។

### គោលបំណង

- គោលបំណងទី១ ៖ ពង្រឹងប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារជាតិ
- គោលបំណងទី២ ៖ ពង្រឹងការងារអធិការកិច្ច និងការអនុវត្តបទដ្ឋានសុវត្ថិភាព និងសុខភាពការងារ
- គោលបំណងទី៣ ៖ ជំរុញអង្គការនិយោជក និងអង្គការកម្មករនិយោជិត ចូលរួមសកម្មភាពសុវត្ថិភាព និងសុខភាពការងារ
- គោលបំណងទី៤ ៖ រៀបចំ និងអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់
- គោលបំណងទី៥ ៖ ជំរុញឱ្យមានការការពារផ្នែកសុវត្ថិភាព និងសុខភាពការងារ ទៅដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គោលបំណងទី៦ ៖ គាំទ្រ និងជំរុញកិច្ចសហការផ្នែកសុវត្ថិភាព និងសុខភាពការងារលើការងារកុមារ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅតាមសហគ្រាស គ្រឹះស្ថាន។

## ៣. យន្តការរៀបចំបទប្បញ្ញត្តិ ស្តីពីសុវត្ថិភាព និងសុខភាពការងារ

កម្មវិធីជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ ត្រូវបានបង្កើតឡើង ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយពិគ្រោះយោបល់ជាមួយគណៈកម្មាធិការត្រីភាគី។ កម្មវិធីនេះ ត្រូវបានពិនិត្យ និងវាយតម្លៃជាទៀងទាត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈកម្មាធិការត្រីភាគី។ គោលនយោបាយជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ អនុវត្តតាមនីតិវិធីស្រដៀងគ្នានឹងកម្មវិធីជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារផងដែរ។ បទប្បញ្ញត្តិនីមួយៗអនុវត្តតាមនីតិវិធី និងដំណើរការក្នុងការរៀបចំនិងធ្វើសេចក្តីព្រាងដូចខាងក្រោម៖

**តារាងទី១៖ យន្តការរៀបចំបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងសុខភាពការងារ**

| បទប្បញ្ញត្តិ | យន្តការ |
|---|---|
| រដ្ឋធម្មនុញ្ញ | ច្បាប់កំពូល |
| អនុសញ្ញាអន្តរជាតិ | បន្ទាប់ពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលមានឥទ្ធិពលដល់ច្បាប់ក្នុងស្រុក និងជាមូលដ្ឋានសម្រាប់សេចក្តីសម្រេចចិត្តរបស់តុលាការ |

| | |
|---|---|
| ច្បាប់ | ច្បាប់ដែលព្រាងដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឬស្នើដោយរដ្ឋសភាដែលត្រូវអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា មុននឹងត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ |
| ព្រះរាជក្រឹត្យ | ចេញដោយព្រះមហាក្សត្រ |
| អនុក្រឹត្យ | ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី បន្ទាប់ពីអនុម័តដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឬកិច្ចប្រជុំគណៈរដ្ឋមន្ត្រី |
| ប្រកាស | ចេញដោយរដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល |
| សេចក្ដីសម្រេច | ការសម្រេចធ្វើឡើងដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬអភិបាលខេត្ត |
| សារាចរ | ចេញដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីដើម្បីពន្យល់ ឬបញ្ជាក់ពីវិធានការណ៍ ឬផ្ដល់ការណែនាំ |
| ដីការ | បទបញ្ជាចេញដោយអភិបាលខេត្ត |

### ៤. នាយកដ្ឋានពេទ្យការងារ

នាយកដ្ឋានពេទ្យការងារ ជាអង្គភាពជំនាញមានតួនាទី និងភារកិច្ចពាក់ព័ន្ធផ្នែកសុវត្ថិភាព និងសុខភាពការងារនៅក្នុងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ ព្រមទាំងយុទ្ធសាស្ត្រជាតិ ស្ដីពីសុវត្ថិភាព និងសុខភាពការងារ។

តួនាទី និងទំនួលខុសត្រូវ

យោងតាមអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅជំពូកទី៦ មាត្រា១៩ អំពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់នាយកដ្ឋានពេទ្យការងារដូចខាងក្រោម៖

- តាក់តែងអត្ថបទច្បាប់ និងបទបញ្ញាការងារពាក់ព័ន្ធដល់អនាម័យការងារ និងបច្ចេកទេសសន្តិសុខការងារក្នុងការការពារទប់ស្កាត់រាល់ហានិភ័យវិជ្ជាជីវៈរបស់កម្មករនិយោជិត
- ចងក្រងឯកសារបច្ចេកទេសក្នុងវិស័យអនាម័យ និងសន្តិសុខការងារ ធ្វើការផ្សព្វផ្សាយអប់រំជាប្រចាំដល់កម្មករនិយោជិតដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស
- ឃ្លាំមើលជាប្រចាំអំពីសុខភាពកម្មករនិយោជិត ដែលប៉ះពាល់ឬខូចខាតដោយសារប្រកបការងារ
- រៀបចំ ត្រួតពិនិត្យ វាយតម្លៃ និងទាក់ទងជាប្រចាំនូវរាល់សកម្មភាពរបស់អង្គភាពពេទ្យការងារ និងត្រួតពិនិត្យពេទ្យនៅតាមសហគ្រាស គ្រឹះស្ថាន ជាពិសេសគ្រប់គ្រងលើការងារសីលធម៌វិជ្ជាជីវៈពេទ្យ

- ទាក់ទងជាមួយបណ្ដាប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿនក្នុងការស្រាវជ្រាវលើគោលនយោបាយ និងបច្ចេកទេសខាងអនាម័យ និងសន្តិសុខការងារ
- ពិនិត្យសុខភាពកម្មករនិយោជិតមុនពេលចូលធ្វើការជាកាលិក ឬសារជាថ្មីទៅតាមសំណូមពរចាំបាច់ និងរៀបចំឯកសារសុខភាពឱ្យបានត្រឹមត្រូវ
- បណ្ដុះបណ្ដាល ផ្សព្វផ្សាយ និងអប់រំស្ដីពីសុវត្ថិភាព និងសុខភាពការងារដល់មន្ត្រីអធិការកិច្ចការងារ អធិការពេទ្យការងារ និយោជក កម្មករនិយោជិត គ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ
- ជំរុញលើកទឹកចិត្ត និងគាំទ្រខាងហិរញ្ញវត្ថុ ចំពោះការសិក្សាវិស័យសុខាភិបាលពាក់ព័ន្ធដល់សុវត្ថិភាព និងសុខភាពការងាររបស់កម្មករនិយោជិត។

**រូបភាពទី២៖ អង្គការលេខនៃនាយកដ្ឋានពេទ្យការងារ**




## ៥. រចនាសម្ព័ន្ធជាតិត្រីភាគី ស្ដីពីសុវត្ថិភាព និងសុខភាពការងារ

គណៈកម្មាធិការត្រីភាគីជាតិ ត្រូវបានបង្កើតឡើងដោយផ្អែកលើប្រធានបទដែលទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ។

### ៥.១. គណៈកម្មការប្រឹក្សាការងារ

គណៈកម្មការប្រឹក្សាការងារ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ ជាយន្តការពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិសម្រាប់ដោះស្រាយបញ្ហាក្នុងវិស័យការងារ រួមទាំងបញ្ហាសុវត្ថិភាព និងសុខភាពការងារ

នៅកម្ពុជា។ គណៈកម្មការប្រឹក្សាការងាររៀបចំការប្រជុំចាំបាច់យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ កិច្ចប្រជុំ អាចធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ តាមគំនិតផ្តួចផ្តើមរបស់ប្រធានគណៈកម្មការ ឬតាមសំណើរបស់អនុប្រធានម្នាក់។

គណៈកម្មការប្រឹក្សាការងារ មានកាតព្វកិច្ច ស្រាវជ្រាវរាល់បញ្ហាដែលទាក់ទងមុខរបរនៃកម្មករនិយោជិត ប្រាក់ឈ្នួល ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ចលនាកម្លាំងពលកម្មក្នុងប្រទេស ទេសន្តរប្រវេសន៍ ការរៀបចំឱ្យរឹតតែប្រសើរឡើងនូវលក្ខខណ្ឌខាងសម្ភារ និងស្មារតីនៃកម្មករនិយោជិត ព្រមទាំងបញ្ហាសុវត្ថិភាព និងសុខភាពការងារ។

❖ ការទទួលខុសត្រូវ

- លើកយោបល់ណែនាំអំពីអត្រាបៀវត្សអប្បបរមាដែលត្រូវធានា
- ផ្តល់យោបល់ជាមុនដើម្បីពង្រីកដែនអនុវត្តអនុសញ្ញារួម ឬក្នុងករណីដែលគ្មានអនុសញ្ញារួមទេ ផ្តល់យោបល់ជាយថាហេតុជាមុនចំពោះបទបញ្ជានៃលក្ខខណ្ឌមុខរបរនៅក្នុងវិជ្ជាជីវៈមួយ ឬនៅក្នុងវិស័យសកម្មភាពណាមួយជាក់លាក់។

❖ មូលដ្ឋានច្បាប់

ច្បាប់ស្តីពីការងារ ជំពូកទី១៥ មាត្រា៣៥៧។

### ៤.២. គណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ

គណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ ដែលសរសេរអក្សរកាត់ថា គ.ជ.ស.ក គឺជាយន្តការត្រីភាគីមួយផ្សេងទៀតសម្រាប់ពិគ្រោះយោបល់ សម្របសម្រួល សហប្រតិបត្តិការ តាមដាន និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហាសុវត្ថិភាព និងសុខភាពការងារ។ ប្រធានគណៈកម្មាធិការ គឺរដ្ឋមន្ត្រី ឬជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណៈកម្មាធិការនេះ មានតួនាទី និងភារកិច្ចចម្បងៗក្នុងការពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយ បទប្បញ្ញត្តិ និងផែនការសកម្មភាពនានាពាក់ព័ន្ធសុវត្ថិភាព និងសុខភាពការងារ។ ម្យ៉ាងវិញទៀតគណៈកម្មាធិការក៏មានតួនាទីក្នុងការសហការ និងសម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បីកៀងគរធនធានបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពលើកកម្ពស់សុវត្ថិភាព និងសុខភាពការងារ។

❖ ការគ្រប់គ្រងដោយគណៈកម្មាធិការ

គណៈកម្មាធិការ ផ្តល់ការណែនាំ និងទិសដៅស្តីពីគោលនយោបាយសុវត្ថិភាព និងសុខភាពការងារ បទប្បញ្ញត្តិ បទដ្ឋាន ការបណ្តុះបណ្តាល ការលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាព និងសុខភាពការងារ និងការសម្របសម្រួលជាមួយស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ វិស័យឯកជន និង

អង្គការសង្គមស៊ីវិល ក្នុងការកៀងគរហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីគាំទ្រសកម្មភាពសុវត្ថិភាព និងសុខភាពការងារ។

❖ មូលដ្ឋានច្បាប់

- អនុក្រឹត្យលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ
- ប្រកាសលេខ៣២៥ កប/ប្រក ពក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ
- សេចក្តីសម្រេចលេខ ០០១/១៧ គជសក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីសេចក្តីសម្រេចលើការរៀបចំសមាសភាពនៃគណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ។

## ៤.៣. គណៈកម្មាធិការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ

គណៈកម្មាធិការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ ត្រូវបានបង្កើតឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយសារបញ្ហាគ្រឿងញៀនបានកើនឡើង និងមានការទាក់ទងជាមួយជំងឺអេដស៍ គណៈកម្មាធិការត្រីភាគីនេះបានរួមបញ្ចូលបញ្ហាគ្រឿងញៀនជាមួយគណៈកម្មាធិការនេះក្រោមចំណងជើងថ្មី "គណៈកម្មាធិការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ"។ គណៈកម្មាធិការត្រីភាគី រួមមានតំណាង ៦ រូប មកពីតំណាងរាជរដ្ឋាភិបាល អង្គការនិយោជក អង្គការកម្មករនិយោជិត ទីភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យនេះ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសដឹកនាំដោយរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងមកពីអង្គការនិយោជក និងនិយោជិត។ គណៈកម្មាធិការត្រីភាគី ត្រូវបានជួយសម្រួលការងារដោយក្រុមលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន ដែលចាត់តាំងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាត់ចែងរៀបចំកិច្ចប្រជុំយ៉ាងតិច៦ដង ក្នុងមួយឆ្នាំ និងមានអាណត្តិដូចអាណត្តិរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៣ និង២០១៨ រហូតមកដល់បច្ចុប្បន្ន។

❖ ការគ្រប់គ្រងដោយគណៈកម្មាធិការ

គណៈកម្មាធិការត្រីភាគី សម្របសម្រួល និងផ្តល់គោលនយោបាយ ការណែនាំជាយុទ្ធសាស្ត្រ និងការអប់រំអំពីបញ្ហាជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ។ គណៈកម្មាធិការសម្របសម្រួល

បច្ចេកទេស ផ្តល់ការណែនាំ អំពីជំងឺអេដស៍ និងគ្រឿងញៀនដែលមានដូចជាប្រកាស និងគោលការណ៍ណែនាំស្តីពីការបង្កើតគណៈកម្មការអេដស៍សម្រាប់ក្រុមការងារនៅកន្លែងធ្វើការ។

❖ មូលដ្ឋានច្បាប់

- ប្រកាសលេខ៤២៨/១៩ បក/ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
- ប្រកាសលេខ០១៣/១៦ បក/ប្រក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលត្រីភាគីស្តីពីជំងឺអេដស៍ និងគ្រឿងញៀន
- ប្រកាសលេខ២៥៥ បក/ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលត្រីភាគីស្តីពីជំងឺអេដស៍។

## ៦. យន្តការសម្របសម្រួល និងសហការ

### ៦.១. ថ្នាក់ជាតិ

គោលនយោបាយ និងសកម្មភាពស្តីពីសុវត្ថិភាព និងសុខភាពការងារ នៅថ្នាក់ជាតិត្រូវបានពិភាក្សា និងអភិវឌ្ឍ តាមរយៈកិច្ចសហប្រតិបត្តិការត្រីភាគី។ ក្រៅពីគណៈកម្មាធិការត្រីភាគីថ្នាក់ជាតិ ក្រុមប្រឹក្សាពិគ្រោះយោបល់ សុវត្ថិភាព និងសុខភាពការងារ ជាច្រើនប្រភេទ ត្រូវបានរៀបចំឡើងសម្រាប់ពិគ្រោះយោបល់លើបញ្ហាសុវត្ថិភាព និងសុខភាពការងារ និងការចែករំលែកបទពិសោធន៍ព័ត៌មាន និងចំណេះដឹង។ ឧទាហរណ៍នៅក្នុងវិស័យកាត់ដេរ ក្រុមប្រឹក្សាពិគ្រោះយោបល់សំខាន់ៗត្រូវបានបង្កើតឡើងចំនួន ៧ក្រុម និងគណៈកម្មាធិការ ត្រូវបានបង្កើតឡើងសម្រាប់ពិគ្រោះយោបល់លើសុខភាពកម្មករ។

នៅថ្នាក់ជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការរួមគ្នាលើបញ្ហាសុវត្ថិភាព និងសុខភាពការងារ ដែលទាមទារ ឱ្យមានការចែករំលែកចំណេះដឹង និងជំនាញបច្ចេកទេសរបស់ក្រសួងនីមួយៗ។ ឧទាហរណ៍ ប្រព័ន្ធត្រួតពិនិត្យរួមគ្នាត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការផ្សព្វផ្សាយស្តីពីសុវត្ថិភាព និងសុខភាពការងារប្រកបដោយប្រសិទ្ធភាពនៅកន្លែងធ្វើការ។ សេចក្តីលម្អិតបន្ថែម ត្រូវបានចែងនៅក្នុងផ្នែកទី៧.១ "យន្តការសម្រាប់ធានាការអនុលោមភាព"។ ក្រសួងផ្តោតលើការពង្រឹងទំនាក់ទំនងរវាងថ្នាក់កណ្តាល និងរាជធានីខេត្ត លើការបណ្តុះបណ្តាល និងកម្មវិធីសុវត្ថិភាព និងសុខភាពការងារ ត្រូវបានផ្តល់ជូនមន្ត្រីនៅថ្នាក់ខេត្តដើម្បីអភិវឌ្ឍធនធានមនុស្ស។

កិច្ចសហការរវាងរាជរដ្ឋាភិបាល អង្គការនិយោជក អង្គការកម្មករនិយោជិត អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិដើម្បីផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អ្នកពាក់ព័ន្ធ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសហការជាមួយអង្គការទាំងនេះលើការប្រឹក្សា និងគំនិតផ្តួចផ្តើមធ្វើគោលនយោបាយ។ ការបណ្តុះបណ្តាល និងឧបករណ៍អនុវត្តជាក់ស្តែងជាច្រើនដែលត្រូវបានជ្រើសរើសលើប្រធានបទស្តីពីសុវត្ថិភាព និងសុខភាពការងារ ត្រូវបានបង្កើតឡើងតាមរយៈការសហការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការដៃគូ ។ "ឯកសារកម្រងព័ត៌មានជាតិអាសបេស្តុសកម្ពុជា" គឺជាឯកសារដែលបានមកពីការសហការគ្នាជាមួយ នឹងអង្គការជាដៃគូដែលដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

នៅកម្រិតវិស័យឧស្សាហកម្ម សមាគមឧស្សាហកម្ម មានទំនាក់ទំនងល្អជាមួយរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិតាមរយៈគម្រោង។ កិច្ចសហការស្តីពីសុវត្ថិភាព និងសុខភាពការងារ ដែលត្រូវបានគេពិចារណា និងបង្កើតឡើងជាពិសេសនៅក្នុងវិស័យកាត់ដេរ។ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា មានបណ្តាញទំនាក់ទំនងរឹងមាំ រវាងរាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការជាតិ អង្គការអន្តរជាតិ អង្គការអន្តរជាតិខាងការងារ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ អង្គការនិយោជក សមាគមរោងចក្រកាត់ដេរនៅកម្ពុជា អង្គការកម្មករនិយោជិត និងសហព័ន្ធសហជីពជាតិកម្ពុជា។ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាផ្តល់កម្មវិធីសម្រាប់ការវាយតម្លៃកន្លែងការងារ ការបណ្តុះបណ្តាល និងការប្រឹក្សាផ្នែកសុវត្ថិភាព និងសុខភាពការងារ នៅកម្រិតរោងចក្រ ក៏ដូចជាការស្រាវជ្រាវ និងការតស៊ូមតិនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ ពង្រឹងសកម្មភាពសម្រាប់ការអប់រំនៅរោងចក្រ គឺជាបណ្តាញមួយផ្សេងទៀតរវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការឃែរ ដែលជាអង្គការក្រៅរដ្ឋាភិបាលដោះស្រាយបញ្ហា កង្វះអាហារូបត្ថម្ភ ចំពោះកម្មករនិយោជិត និងការរំលោភសិទ្ធិយេនឌ័រ និងអំពើហិង្សានៅកន្លែងធ្វើការ។

នៅក្នុងវិស័យសំណង់យន្តការសហប្រតិបត្តិការត្រីភាគី កំពុងអភិវឌ្ឍជាបណ្តើរៗ។ នៅឆ្នាំ ២០១៨ ក្រុមប្រឹក្សាគម្រោងនៃអង្គការអន្តរជាតិខាងការងារជប៉ុន បានលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការជាតិសុវត្ថិភាព និងសុខភាពការងារ តំណាងរាជរដ្ឋាភិបាល និយោជក និងអង្គការកម្មករនិយោជិត វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល បានចូលរួមប្រឹក្សាយោបល់។ គោលបំណងនៃក្រុមប្រឹក្សា គឺដើម្បីចែករំលែកការអនុវត្តល្អដែលមានស្រាប់ទាក់ទងនឹងសុវត្ថិភាព និងសុខភាពការងារ នៅកម្រិតសហគ្រាស និងពង្រឹងក្របខ័ណ្ឌច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ តាមរយៈដំណើរការពិគ្រោះយោបល់ត្រីភាគី និងលើកកម្ពស់វិធានការជាក់ស្តែង ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ការងារ និងការរងរបួស។

### ៦.២. ថ្នាក់រោងចក្រ សហគ្រាស

គណៈកម្មការសុវត្ថិភាព និងសុខភាពការងារ ថ្នាក់រោងចក្រ សហគ្រាសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តសកម្មភាព សុវត្ថិភាព និងសុខភាពការងារ។ រាជរដ្ឋាភិបាលផ្ដល់ការគាំទ្របន្ថែមដល់កម្មករនិយោជិត ក្នុងពេលដែលធ្វើការជាមួយអង្គការពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំគោលការណ៍ណែនាំក្នុងការគាំទ្រដល់សកម្មភាពរបស់គណៈកម្មការសុវត្ថិភាព និងសុខភាពការងារ។ ការគាំទ្រថ្នាក់ជាតិ និងថ្នាក់រោងចក្រ សហគ្រាស គឺចាំបាច់ដើម្បីទ្រទ្រង់សកម្មភាពរបស់គណៈកម្មការសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ។

## ៧. ប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារ៖ មធ្យោបាយ និងឧបករណ៍

### ៧.១. យន្តការដើម្បីធានាការអនុលោមតាមច្បាប់

៧.១.១. ការទទួលខុសត្រូវរបស់ក្រសួងក្នុងការធ្វើអធិការកិច្ចសុវត្ថិភាព និងសុខភាពការងារ

ការត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ចការងារផ្នែកសុវត្ថិភាព និងសុខភាពការងារ ត្រូវបានធ្វើដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅថ្នាក់កណ្ដាល និងថ្នាក់មន្ទីររាជធានី ខេត្តទាំង២៥។ នាយកដ្ឋានពេទ្យការងារ ទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ចការងារផ្នែកសុវត្ថិភាព និងសុខភាពការងារនៅតាមរោងចក្រ សហគ្រាស។

❖ មូលដ្ឋានច្បាប់៖

អនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅជំពូកទី៦ មាត្រា១៥ អំពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់នាយកដ្ឋានអធិការកិច្ចការងារ និងមាត្រា១៩ អំពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់នាយកដ្ឋានពេទ្យការងារ។

❖ អធិការកិច្ចការងារតែមួយ

អធិការកិច្ចការងារតែមួយមានអង្គភាពចំនួន ៨ ចំណុះឱ្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលមានដូចខាងក្រោម៖

- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានវិវាទការងារ
- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
- នាយកដ្ឋានការងារកុមារ

- នាយកដ្ឋានពេទ្យការងារ
- នាយកដ្ឋានបណ្តុះបណ្តាល
- បេឡាជាតិសន្តិសុខសង្គម
- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា។

❖ ផ្នែកអធិការកិច្ចការងារតែមួយ

នៅថ្នាក់ជាតិ អធិការកិច្ចការងារតែមួយត្រូវបានបែងចែកជាក្រុម។ ឧទាហរណ៍នៅឆ្នាំ ២០១៨ អធិការកិច្ចការងារតែមួយត្រូវបានបែងចែកជា ១៣ ក្រុម ដែលក្រុមនីមួយៗមានសមាជិក ៧នាក់ ដោយមានមន្ត្រី០១នាក់ ត្រូវបានតែងតាំងជាប្រធានក្រុម។ លើសពីនេះក្រុមអន្តរាគមន៍ចំនួន ២ ក៏ត្រូវបានបង្កើតឡើងផងដែរ។ ក្រុមអន្តរាគមន៍នីមួយៗមានប្រធាន ០១នាក់ និងអនុប្រធាន០១នាក់ និងមានសមាជិកពី១០នាក់ ទៅ១១នាក់។

❖ ក្រុមអន្តរាគមន៍

ក្រុមអន្តរាគមន៍ត្រួតពិនិត្យ លើក្រុមអធិការកិច្ចការងារតែមួយទាំងអស់។ ក្រុមអន្តរាគមន៍ទី ១ ទទួលខុសត្រូវក្នុងការសម្របសម្រួល និងត្រួតពិនិត្យក្រុមអធិការកិច្ចការងារតែមួយចាប់ពីក្រុមទី ១ ដល់ក្រុមទី៦។ ក្រុមអន្តរាគមន៍ទី ២ គ្រប់គ្រងក្រុមអធិការកិច្ចការងារ តែមួយចាប់ពីក្រុមទី ៧ ដល់ក្រុមទី១៣ ។

❖ ស្ថានភាពបច្ចុប្បន្នអំពីអធិការកិច្ចការងារតែមួយ

- ក្រុមអធិការកិច្ចការងារតែមួយថ្មីចំនួន ៤ក្រុម ត្រូវបានរៀបចំឡើង។ ក្រុមថ្មីនេះតាមដានបញ្ហាជួលសន្លប់និងការត្រួតពិនិត្យនៅក្នុងវិស័យសំណង់ ឡឥដ្ឋ និងវិស័យសេវាកម្សាន្ត។ ក្រុមអធិការកិច្ចការងារតែមួយមានសមាជិក ៧ នាក់ក្នុងមួយក្រុម។

❖ មូលដ្ឋានច្បាប់៖

- លិខិតផ្ទេរសិទ្ធិលេខ ១០២/១៩ ចុះថ្ងៃទី ១៩ ខែសីហាឆ្នាំ ២០១៩
- នៅឆ្នាំ ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសថ្មីស្តីពីក្រុមអធិការកិច្ចការងារ ដែលមានមន្ត្រីមកពីអង្គភាពចំនួន ៣ រួមមាននាយកដ្ឋានពេទ្យការងារ នាយកដ្ឋានអធិការកិច្ចការងារ និងបេឡាជាតិសន្តិសុខសង្គម។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងដែលផ្តោតលើវិស័យផលិតកម្ម ការងារ សេវាកម្សាន្ត និងបរិស្ថាន ដោយមានសមាសភាព ក្រុមអធិការកិច្ចមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងបរិស្ថាន និង

ក្រុមអធិការកិច្ចមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន។

❖ មូលដ្ឋានច្បាប់៖

បទបញ្ជាអន្តរក្រសួងលេខ ០៧២ / ២០ ចុះថ្ងៃទី ២៧ ខែកុម្ភៈឆ្នាំ ២០២០ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងសម្រាប់ឧស្សាហកម្ម ទេសចរណ៍។ បទបញ្ជាអន្តរក្រសួងលេខ០៧៣/ ២០ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងសម្រាប់វិស័យផលិតកម្ម ។

៧.១.២. ប្រព័ន្ធអធិការកិច្ចការងារ

ការធ្វើអធិការកិច្ចការងារមាន ៣ ប្រភេទ៖

១-អធិការកិច្ចការងារសាមញ្ញ ៖ ធ្វើឡើងជាទៀងទាត់ ដោយមានការជូនដំណឹងជាមុនដល់ម្ចាស់ នាយក រោងចក្រ សហគ្រាស។ លិខិតជូនដំណឹងមានខ្លឹមសារ បញ្ជាក់នូវកម្មវត្ថុនៃការចុះធ្វើអធិការកិច្ចការងារដូចជា៖

- ឯកសារចាំបាច់ដែលត្រូវដាក់ឱ្យអធិការកិច្ចការងារត្រួតពិនិត្យ
- លក្ខខណ្ឌការងារដែលត្រូវត្រួតពិនិត្យ។

២- អធិការការងារពិសេស ៖ ធ្វើឡើងដោយគ្មានជូនដំណឹងជាមុន បន្ទាប់ពីអធិការការងារបានរកឃើញភាពមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធដែលបានកំណត់ក្នុងរបាយការណ៍អធិការកិច្ចការងារ និងលិខិតដាក់កំហិត។ ក្នុងករណីឃើញភាពមិនអនុលោមនៅតែបន្តកើតមាន ម្ចាស់ នាយក រោងចក្រ សហគ្រាស ត្រូវចាត់ទុកថាមិនគោរពច្បាប់ នឹងត្រូវផ្តន្ទាទោស និងពិន័យជាប្រាក់តាមច្បាប់ជាធរមាន ព្រមទាំងចាត់វិធានការដទៃទៀតពីក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

៣- អធិការកិច្ចការងារពិសេសក្រៅកម្មវិធី ៖ គឺធ្វើឡើងក្រោយពីមានបណ្តឹង សំណើ ហានិភ័យនានា ការចាំបាច់របស់ក្រសួងជំនាញ ឬទទួលបានព័ត៌មានពីសារព័ត៌មាន និងបណ្តាញព័ត៌មានទំនាក់ទំនងសង្គមពីករណីមិនបានអនុវត្តត្រឹមត្រូវរបស់ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស និងកម្មករនិយោជិតអំពីការរំលោភបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

នៅរាជធានីភ្នំពេញមានការបែងចែកគ្នាបានយ៉ាងច្បាស់អំពីអធិការកិច្ចការងារ និងអធិការផ្នែកសុវត្ថិភាព និងសុខភាពការងារ។ នៅតាមបណ្តាខេត្ត គឺមានការបញ្ចូលគ្នារវាងអធិការកិច្ចការងារ និងសុវត្ថិភាព និងសុខភាពការងារ។

**រូបភាពទី៣៖ ប្រព័ន្ធអធិការកិច្ចការងារ**




- ❖ គោលដៅអ្នកធ្វើអធិការកិច្ច

អធិការកិច្ចការងារ ត្រូវមើល និងត្រួតពិនិត្យកន្លែងធ្វើការនៅតាមរោងចក្រ សហគ្រាសផ្តែកលើជំនាញសុវត្ថិភាព និងសុខភាពការងារ។ អធិការការងារ ត្រូវជូនដំណឹងដល់និយោជកជាមុន អំពីការរំលោភបំពានដែលបានរកឃើញ មុនពេលសរសេរក្នុងរបាយការណ៍។ ការជូនដំណឹងជាមុននេះ គឺដើម្បីផ្តល់ការព្រមានដល់និយោជកឱ្យចាត់វិធានការកែតម្រូវមុនពេលផុតកំណត់នៃសេចក្តីជូនដំណឹង។ ទោះយ៉ាងណាប្រសិនបើអធិការកិច្ចការងារ ឃើញថាការរំលោភបំពាននោះមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុវត្ថិភាព និងសុខភាពរបស់កម្មករ នោះអធិការត្រូវតែរាយការណ៍ពីការរំលោភបំពានជាផ្លូវការដោយមិនចាំបាច់រង់ចាំការផុតកំណត់នៃសេចក្តីជូនដំណឹង។

❖ ការត្រួតពិនិត្យនៃអធិការកិច្ចការងារ

មន្ត្រីអធិការកិច្ចការងារ ជាមន្ត្រីរាជការ ឬមន្ត្រីនគរបាលយុត្តិធម៌ ដែលមានតួនាទីក្នុងការចុះធ្វើអធិការកិច្ចការងារតាមរោងចក្រ សហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជា ។

❖ មូលដ្ឋានច្បាប់៖

ច្បាប់ស្តីពីការងារ មាត្រា ២៣៣ ដល់ មាត្រា២៣៧

❖ ការអនុវត្តបទប្បញ្ញត្តិស្តីពីក្រមព្រហ្មទណ្ឌ

ប្រសិនបើមានការរំលោភបំពានលើផ្នែកសុវត្ថិភាព និងសុខភាពការងារ ត្រូវបានរកឃើញនៅក្នុងដំណើរការនៃអធិការកិច្ចនោះ អ្នកតំណាងក្រុមហ៊ុន នាយកក្រុមហ៊ុន អ្នកគ្រប់គ្រង ឬនាយកប្រតិបត្តិដែលពាក់ព័ន្ធ ត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ ដោយកំណត់ប្រាក់ឈ្នួលស្មើនឹង ៣០ ទៅ ១២០ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ក្នុងករណីធ្ងន់ធ្ងរបំផុតអ្នកប្រព្រឹត្តបទល្មើសអាចត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

❖ មូលដ្ឋានច្បាប់៖

ច្បាប់ស្តីពីការងារ មាត្រា៣៧៥ មាត្រា៣៧៦ និងមាត្រា៣៧៧

### ៧.១.៣. វិសាលភាពនៃការគ្របដណ្តប់

អធិការកិច្ចការងារ គឺគ្របដណ្តប់ការងារទាំងអស់នៅតាមសហគ្រាស ក្រុមហ៊ុន ក្នុងវិស័យឯកជនដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ នៃប្រទេសកម្ពុជាដូចមានកំណត់នៅក្នុងជំពូកទី១ មាត្រា១។

### ៧.១.៤. តួនាទីរបស់មន្ត្រីអធិការកិច្ចការងារ

- ធានាដល់ការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីសហជីព លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ
- ជូនដំណឹង និងផ្តល់ដំបូន្មានបច្ចេកទេសចំពោះនិយោជក និងកម្មករនិយោជិតអំពីមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីគោរពបទប្បញ្ញត្តិច្បាប់
- ផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ចនូវការមិនគប្បី ឬការរំលោភផ្សេងៗ ដែលពុំទាន់មានបទប្បញ្ញត្តិច្បាប់ជាធរមាននៅឡើយ
- ជូនយោបល់អំពីបញ្ហាទាក់ទង នឹងការរៀបចំ ឬកែប្រែសហគ្រាស និងអង្គការចាត់តាំង ដែលបានអនុញ្ញាតអំពីអាជ្ញាធររដ្ឋបាល ហើយដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលទាក់ទងនឹងលក្ខខណ្ឌជីវភាពនៃកម្មករនិយោជិត និងគ្រួសារនៃជនទាំងនេះ

- ធ្វើការត្រួតពិនិត្យបច្ចេកទេសខាងអនាម័យការងារ (កម្រិតពន្លឺ សំឡេង ធូលី រំញ័រ និងហានិភ័យផ្នែករូបសាស្ត្រដែលបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗទៀត)
- បង្កើតបណ្តាញសុវត្ថិភាព និងសុខភាពដល់រោងចក្រ សហគ្រាស
- លើកកម្ពស់ការពិនិត្យសុខភាពដល់កម្មករនិយោជិត
- បង្កើតក្រុមការងារ ឬគណៈកម្មការអេដស៍ និងគ្រឿងញៀននៅតាមរោងចក្រ សហគ្រាស
- ផ្តល់ការការពារសុវត្ថិភាព និងសុខភាពការងារដល់កម្មករនិងវិធានការណ៍ការពារគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
- ណែនាំនិយោជក និងកម្មករនិយោជិតអំពីបទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ
- ណែនាំពីវិធានការណ៍ដែលបានដាក់ចេញ នៅក្នុងពេលមានការរីករាលដាលនៃជំងឺឆ្លង
- អង្កេតគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ និងវិធានការណ៍ការពារគ្រោះថ្នាក់ការងារ
- អនុវត្តការចុះធ្វើអធិការកិច្ច និងពិន័យចំពោះការរំលោភច្បាប់ និងបទប្បញ្ញត្តិ។

៧.១.៥. ចំនួននៃការធ្វើអធិការកិច្ចការងារ

**តារាងទី២៖ ចំនួនការធ្វើអធិការកិច្ច នៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត**

| ឆ្នាំ | ចំនួនមន្ត្រីអធិការកិច្ចការងារ | | ចំនួនសរុប | ភេទ | |
|---|---|---|---|---|---|
| | ថ្នាក់កណ្តាល | ថ្នាក់ខេត្ត | | ប្រុស | ស្រី |
| ២០១៣ | ៤៤ | ២៥០ | ២៩៤ | ២៦៥ | ២៩ |
| ២០១៤ | ១៥៩ | ២៧២ | ៤៣១ | ៣៨៦ | ៤៥ |
| ២០១៥ | ១៤៨ | ២៩៦ | ៤៤៤ | ៣៩១ | ៥៣ |
| ២០១៦ | ១៥៨ | ៤២៧ | ៥៨៥ | ៥១០ | ៧៥ |
| ២០១៧ | ១៣៥ | ៤៣៦ | ៥៧១ | ៤៨៦ | ៨៥ |
| ២០១៨ | ១១០ | ៤៧៤ | ៥៨៤ | ៤៩៧ | ៨៧ |
| ២០១៩ | ១៤៦ | ៤៦០ | ៦០៦ | ៥១១ | ៩៥ |

៧.១.៦. ចំនួននៃការចុះធ្វើអធិការកិច្ចការងារនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត

**តារាង៣៖ ចំនួនការធ្វើអធិការកិច្ច នៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត**

| សកម្មភាព | ឆ្នាំ | | | | | | |
|---|---|---|---|---|---|---|---|
| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
| ចំនួនអធិការកិច្ចសាមញ្ញ | ២,២១៩ | ៦,៨១១ | ៨,៧៨៩ | ៨,១៩៧ | ៨,៦៨៩ | ៨,៤០២ | ៨,០៩៥ |
| អធិការកិច្ចពិសេស | ២២៧ | ៣៨០ | ៣៣៣ | ៥៦៦ | ៥៩៥ | ៦១៩ | ៥៦១ |
| អធិការកិច្ចពិសេស (មិនមានការជូនដំណឹងជាមុន) | - | - | ២១៧ | ៣៧៩ | ៤៣៣ | ៣២៩ | ២៦៦ |
| ផ្តល់ដំបូន្មាន | ២៩៥ | ៨០៥ | ៦៤៨ | ៨៤២ | ៨៩៣ | ១០០ | ៩៧៧ |
| ពិន័យ | - | - | ៣០ | ៦០ | ៨១ | ១៦ | ១៣៦ |
| ប្តឹងទៅតុលាការ | - | - | - | - | ០៥ | ០៤ | ០៦ |

*ប្រភព៖ នាយកដ្ឋានអធិការកិច្ចការងារ*

៧.១.៧. កិច្ចសហការក្នុងការចុះធ្វើអធិការកិច្ចការងារ

នៅពេលដែលគ្រោះថ្នាក់កើតឡើង នៅរោងចក្រ សហគ្រាស មន្ត្រីអធិការកិច្ចមានកិច្ចសហការជាមួយមន្ត្រីជំនាញនៃអង្គភាពដទៃទៀតនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត (ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់) និងអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការអង្កេត។ ដោយផ្អែកលើកម្មវិធីនៃការចុះអធិការកិច្ចនាពេលបច្ចុប្បន្ន ការធ្វើអធិការកិច្ចត្រូវបានពង្រីកវិសាលភាពនៃការគ្របដណ្តប់លើវិស័យចាំបាច់បន្ថែមទៀត។

៧.១.៨. បញ្ជីផ្ទៀងផ្ទាត់ និងឧបករណ៍សម្រាប់ធ្វើអធិការកិច្ចការងារ

មន្ត្រីអធិការកិច្ច បានប្រើប្រាស់នូវរបាយការណ៍ស្តីពីអធិការកិច្ចការងារសម្រាប់ធ្វើជាបញ្ជីផ្ទៀងផ្ទាត់ និងឧបករណ៍សម្រាប់វាស់វែងមួយចំនួននៅពេលចុះធ្វើអធិការកិច្ចការងារ(វាស់ពន្លឺ សំឡេង កម្តៅ)។

៧.១.៩. ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារ

យុទ្ធសាស្ត្រជាតិសម្រាប់បណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារ និងអភិបាលការងារ មិនទាន់បានអភិវឌ្ឍនៅឡើយនាពេលបច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកម្មវិធីជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានផែនការក្នុងការអភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់មន្ត្រីអធិការកិច្ចការងារ។ ការបណ្តុះបណ្តាលសម្រាប់មន្ត្រីអធិការកិច្ច ផ្នែកសុវត្ថិភាព និងសុខភាពការងារ រួមបញ្ចូលដូចខាងក្រោម៖

- ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារ
- ក្រមសីលធម៌មន្ត្រីអធិការកិច្ចការងារ

- របាយការណ៍អធិការកិច្ចការងារ និងគោលការណ៍ណែនាំ
- ការរៀបចំ និងរបៀបនៃការចុះធ្វើអធិការកិច្ច
- ការយល់ដឹងអំពីមូលដ្ឋានគ្រឹះសុវត្ថិភាព និងសុខភាពការងារ
- ការគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការងារ
- ការប្រើប្រាស់ឧបករណ៍ និងវិភាគទិន្នន័យសុវត្ថិភាព និងសុខភាពការងារ
- គោលនយោបាយ និងស្តង់ដារសុវត្ថិភាព។

ការកសាងសមត្ថភាពដើម្បីលើកកម្ពស់ជំនាញអធិការកិច្ចការងារ និងចំណេះដឹងទាក់ទងនឹងផ្នែកសុវត្ថិភាព និងសុខភាពការងារនៅក្នុងប្រទេស ចាំបាច់ត្រូវការអភិវឌ្ឍបន្ថែមទៀត។

**៧.២. មជ្ឈមណ្ឌលព័ត៌មានសុវត្ថិភាព និងសុខភាពការងារ**

នៅថ្នាក់ជាតិ ស្ថាប័នរាជរដ្ឋាភិបាល មានកិច្ចសហការគ្នាលើព័ត៌មានផ្នែកសុវត្ថិភាព និងសុខភាពការងារដើម្បីឱ្យមានការប្រសើរឡើង និងការលើកកម្ពស់ការយល់ដឹង តាមរយៈការប្រើប្រាស់សេវាបណ្តាញសង្គម គេហទំព័រ និងហត់ឡាញ។ មានការសហការគ្នាជាលក្ខណៈអន្តរជាតិដែលមានការចូលរួមពីក្រសួងស្ថាប័ននៃប្រទេសអាស៊ាន ដែលមានបណ្តាញឈ្មោះថា អាស៊ានអូសូណេត។

ក្នុងកិច្ចសហការជាមួយស្ថាប័នអន្តរជាតិ និងម្ចាស់ជំនួយជាទ្វេភាគី ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ បានបង្កើតឧបករណ៍មួយចំនួនដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការងារ។ នាយកដ្ឋានពេទ្យការងារ បានផលិតខិតប័ណ្ណចំនួន ២,០០០ សន្លឹក និងបដាចំនួន ៣,០០០ផ្ទាំង ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងដល់កម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ទាក់ទងនឹងសុវត្ថិភាពសារធាតុគីមី ការលើកដាក់ទម្ងន់ និងការប្រើប្រាស់សម្ភារការពារបុគ្គល ក្រោមជំនួយរបស់ទីភ្នាក់ងារសុវត្ថិភាព និងសុខភាពការងារកូរ៉េ និងបដា ចំនួន ១,២០០ផ្ទាំង ទាក់ទងនឹងសុវត្ថិភាពអគ្គិសនី ក្រោមកិច្ចសហការជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការអន្តរជាតិខាងការងារ។

**តារាងទី៤៖ គេហទំព័រព័ត៌មានផ្នែកសុវត្ថិភាព និងសុខភាពការងារ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

| **ស្ថាប័ន** | **មាតិកានៃព័ត៌មានស្តីពីសុវត្ថិភាព និងសុខភាពការងារ** | **គេហទំព័រ** |
|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ច្បាប់ គោលនយោបាយ ប្រព័ន្ធអធិការកិច្ច និងស្ថិតិគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ | http://www.mlvt.gov.kh |
| បេឡាជាតិសន្តិសុខសង្គម | ច្បាប់ កម្មវិធី ប្រាក់សោធន របបធានារ៉ាប់រងផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងស្ថិតិនៃគ្រោះថ្នាក់ការងារ និងជំងឺ | http://www.nssf.gov.kh |

### ៧.៣. សេវាផ្នែកសុវត្ថិភាព និងសុខភាពការងារ

តាមតម្រូវការរបស់រោងចក្រ សហគ្រាស រាល់បទប្បញ្ញត្តិទាំងអស់ និយោជកត្រូវតែរៀបចំ និងចងក្រងទុក ដូចជាវិធានការការពារនូវហានិភ័យទាំងឡាយដែលមាននៅក្នុងរោងចក្រ សហគ្រាស ការផ្តល់នូវវគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិត និងគ្រូពេទ្យប្រចាំគិលានដ្ឋានរបស់រោងចក្រ សហគ្រាស ការការពារហានិភ័យសុខភាព ការសង្គ្រោះបឋម សេវាសង្គ្រោះបន្ទាន់ និងសេវាសុខភាពផ្សេងៗ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់និយោជក។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសលេខ១៧៦ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព ចុះនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ទាមទារឱ្យនិយោជកផ្តល់នូវការអប់រំណែនាំស្តីពីសុវត្ថិភាព និងសុខភាពការងារទៅដល់បុគ្គលិក កម្មករនិយោជិតចូលធ្វើការដំបូង នៅពេលផ្លាស់ប្តូរការងារ ឬការផ្លាស់ប្តូរប៉ុស្តិ៍ការងារ ឬការឈប់សម្រាកពីការងារក្នុងរយៈពេល១ខែយ៉ាងយូរ។

ចំពោះតម្រូវការនៃគ្រូពេទ្យប្រតិបត្តិការ ឬគ្រូពេទ្យក្នុងរោងចក្រ សហគ្រាស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញក្នុងប្រកាសរួមរវាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល លេខ៣៣០ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី ការរៀបចំគិលានដ្ឋានសហគ្រាស។ ចំនួននៃបុគ្គលិក សុខាភិបាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានកំណត់ទៅតាមចំនួនកម្មករនិយោជិតដែលមាននៅក្នុងរោងចក្រ សហគ្រាស។

**តារាងទី៥៖ ចំនួន និងគុណភាពនៃបុគ្គលិកសុខាភិបាល**

| ចំនួនកម្មករនិយោជិតក្នុងរោងចក្រ សហគ្រាស | ចំនួនគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា | ចំនួនគ្រូពេទ្យ | វត្តមានអប្បបរមារបស់គ្រូពេទ្យ សម្រាប់មួយវេន ៨ម៉ោង |
|---|---|---|---|
| ៥០-៣០០ | ១នាក់ | វេជ្ជបណ្ឌិត១នាក់ឬ គ្រូពេទ្យមធ្យម១នាក់ | ២ម៉ោង |
| ៣០១-៦០០ | ១នាក់ | វេជ្ជបណ្ឌិត១នាក់ | ២ម៉ោង |
| ៦០១-៩០០ | ២នាក់ | វេជ្ជបណ្ឌិត១នាក់ | ៣ម៉ោង |
| ៩០១-១៤០០ | ២នាក់ | វេជ្ជបណ្ឌិត១នាក់ | ៤ម៉ោង |
| ១៤០១-២០០០ | ២នាក់ | វេជ្ជបណ្ឌិត១នាក់ | ៦ម៉ោង |
| លើសពី២០០០ | ៣នាក់ | វេជ្ជបណ្ឌិត១នាក់ | ៨ម៉ោង |

អធិការផ្នែកសុវត្ថិភាព និងសុខភាពការងារ បានផ្តល់ដំបូន្មានស្តីពីសុវត្ថិភាព និងសុខភាពការងារ ដោយផ្អែកលើការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនៅកន្លែងធ្វើការដល់រោងចក្រ សហគ្រាស។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាព និងសុខភាពការងារ សម្រាប់មន្ត្រីអធិការកិច្ចការងារផងដែរ។

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ផ្តល់សេវាប្រឹក្សាបច្ចេកទេស និងច្បាប់ពាក់ព័ន្ធសុវត្ថិភាព និងសុខភាពការងារដល់សមាជិករបស់ពួកគេ។ អង្គការកម្មករនិយោជិត ផ្តល់ប្រឹក្សាស្តីពីសុវត្ថិភាព និងសុខភាពការងារដល់សមាជិកគាត់ផងដែរ។

### ៧.៤. ការអប់រំ និងការបណ្តុះបណ្តាលអំពីសុវត្ថិភាព និងសុខភាពការងារ ដោយរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល បានផ្តល់នូវការបណ្តុះបណ្តាលជាច្រើនវគ្គដោយមានកិច្ចសហការពីនិយោជក អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចូលរួមចំណែកក្នុងការផ្តល់ការបណ្តុះបណ្តាលដល់កម្មករនិយោជិតនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម ក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធក៏ដូចជាវិស័យដែលមានហានិភ័យខ្ពស់ដូចជា ផ្នែកផលិតកម្ម និងសំណង់។ ការបណ្តុះបណ្តាល ផ្តោតជាសំខាន់ទៅលើការការពារគ្រោះថ្នាក់ការងារ និងជំងឺ ដោយចេញពីគំនិតផ្តួចផ្តើមជួយខ្លួនឯងរបស់កម្មករនិយោជិត និងនិយោជក ស្របតាមស្ថានភាពបច្ចុប្បន្នស្តីពីសុវត្ថិភាព និងសុខភាពការងារ ។ ដូចគ្នានេះដែរ កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្មករសំណង់ក៏ត្រូវបានពង្រឹងផងដែរ។ នៅឆ្នាំ២០១៩ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការកែលម្អរបៀបធ្វើការនៅការដ្ឋានសំណង់ខ្នាតតូច (WISCON) ដល់មន្ត្រីនាយកដ្ឋានពេទ្យការងារ មន្ត្រីនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត និងសហជីព ដោយសហការជាមួយអង្គការអន្តរ

ជាតិខាងការងារ។ កម្មវិធីបណ្តុះបណ្តាលអំពីសុវត្ថិភាព និងសុខភាពការងារនេះផ្តោតទៅលើគ្រោះថ្នាក់ការងារផ្នែកសំណង់ ក្រោមការដឹកនាំរបស់ក្រសួង ដោយមានការឧបត្ថម្ភពីគម្រោងលើកកម្ពស់ស្តង់ដារសុវត្ថិភាព និងសុខភាពការងារនៅក្នុងវិស័យសំណង់នៅកម្ពុជានៃកម្មវិធីពហុភាគីរបស់ជប៉ុន។

កម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីជំនាញសុវត្ថិភាពសំណង់ ក៏ត្រូវបានប្រព្រឹត្តទៅយ៉ាងរលូនដោយមានការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេសពីទីភ្នាក់ងារសុវត្ថិភាព និងសុខភាពការងារកូរ៉េ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពផ្នែកសុវត្ថិភាព និងសុខភាពការងារផ្នែកសំណង់ដល់មន្ត្រីអធិការកិច្ចការងារ ក្រសួងស្ថាប័នពាក់ព័ន្ធនៅក្នុងខែមិថុនា ឆ្នាំ ២០១៩។ សកម្មភាពបណ្តុះបណ្តាលត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០១៣ដល់២០១៩មានដូចខាងក្រោម៖

**តារាងទី៦៖ សកម្មភាពបណ្តុះបណ្តាលដែលបានអនុវត្តនៅចន្លោះឆ្នាំ២០១៣-២០១៩ មានដូចខាងក្រោម៖**

| កម្មវិធីបណ្តុះបណ្តាល | ឆ្នាំ | ប្រភេទនៃការបណ្តុះបណ្តាល | ចំនួនអ្នកចូលរួម | | | ព័ត៌មានស្តីពីអ្នកចូលរួម |
|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | សរុប | |
| ការកែលម្អរបៀបធ្វើការនៅការដ្ឋានសំណង់ខ្នាតតូច (WISCON) | ២០១០-២០១៩ | គ្រូបង្គោល | ១៩៣ | ៣៣ | ២២៦ | មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២៥ រាជធានីខេត្ត មន្ត្រីនាយកដ្ឋានពេទ្យការងារ និងសហជីព |
| | | ការលើកកម្ពស់ការយល់ដឹង | ៤៧៥ | ១៩៣ | ៦៦៨ | សហជីព អ្នកម៉ៅការ មេការ (ភ្នំពេញ កណ្តាល កំពង់ស្ពឺ សៀមរាប កំពត ព្រះសីហនុ មណ្ឌលគីរី) |
| ការកែលម្អរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ (WISH) | ២០០៩-២០១៥ | គ្រូបង្គោល | ៨ | ៣២ | ៤០ | កំពង់ស្ពឺ ស្វាយរៀង |
| | | ការលើកកម្ពស់ការយល់ដឹង | ១.០៥៥ | ៥៨៦ | ១.៦៤១ | មណ្ឌលគីរី រតនៈគីរី ភ្នំពេញ កណ្តាល សៀមរាប កំពង់ឆ្នាំង តាកែវ កែប និង កំពង់ស្ពឺ |
| ការកែលម្អលក្ខខណ្ឌធ្វើការនៅតាមសហគ្រាសខ្នាតតូច | ២០១៣-២០១៤ | គ្រូបង្គោល | ២៦ | ១៤ | ៤០ | មន្ត្រីនាយកដ្ឋានពេទ្យការងារ មន្ទីរការងាររាជធានីភ្នំពេញ ស្វាយរៀង |

| | | | | | | |
|---|---|---|---|---|---|---|
| (WISE) | | ការលើកកម្ពស់ការយល់ដឹង | ៦៧ | ១៩ | ៨៦ | ព្រៃវែង<br>កំពង់ស្ពឺ<br>កំពង់សោម |
| ការកែលម្អរបៀបធ្វើការងារនិងអភិវឌ្ឍភូមិដ្ឋាន (WIND) | ២០១២-២០១៥ | គ្រូបង្គោល | ១១ | ២៩ | ៤០ | មន្ត្រីនាយកដ្ឋានពេទ្យការងារ<br>និងមន្ទីរការងារខេត្ត (កំពង់ស្ពឺ និងស្វាយរៀង) |
| | | ការលើកកម្ពស់ការយល់ដឹង | ៧០ | ១២៨ | ១៩៨ | កម្មករនិយោជិត (ភ្នំពេញ តាកែវ និងព្រៃវែង ) |

*ប្រភព៖នាយកដ្ឋានពេទ្យការងារ(នពក)*

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតមាននៅកន្លែងធ្វើការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រីកកម្មវិធីបណ្តុះបណ្តាលជាក់លាក់សម្រាប់សង្គ្រោះបឋម ការការពារការដួលសន្លប់ និងកម្មវិធីផ្សេងៗទៀត។

**តារាងទី៧៖ ការលើកកម្ពស់ការយល់ដឹងស្តីពីសុវត្ថិភាព និងសុខភាពការងារ រួមទាំងជំនួយសង្គ្រោះបឋម ដោយផ្អែកលើប្រកាសលេខ១៧៦ ដែលបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៣**

| ឆ្នាំ | ប្រភេទបណ្តុះបណ្តាល | ចំនួនអ្នកចូលរួម | | | ព័ត៌មានអ្នកចូលរួម |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| ២០១៦-២០១៩ | ការលើកកម្ពស់ការយល់ដឹងស្តីពីសុវត្ថិភាព និងសុខភាព ការងារ និងសង្គ្រោះបឋម | ៨,៧៤៥ | ១,២៥១ | ៩,៩៩៦ | កម្មករនិយោជិតទូទាំងប្រទេស |
| | ការកសាងសមត្ថភាពមន្ត្រីមកពីមន្ទីរខេត្ត | ៣០ | ១១ | ៤១ | មន្ត្រីមកពីមន្ទីរខេត្ត |

*ប្រភព៖ នាយកដ្ឋានពេទ្យការងារ(នពក)*

**តារាងទី៨៖ សិក្ខាសាលាស្ដីពីការការពារការដួលសន្លប់នៅកន្លែងធ្វើការ**

| ឆ្នាំ | ចំនួនសហគ្រាស | ចំនួនកម្មករ | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១២ | ១៥ | ២៨.០០០ | ២៥.២០០ |
| ២០១៣ | ៧១ | ១០.៩១៧ | ៩.៨២៥ |
| ២០១៤ | ២៧ | ៣.១០០ | ២.៧៩០ |
| ២០១៥ | ៩០ | ១៣.៤៥០ | ១២.១០៥ |
| ២០១៦ | ៧៧ | ១៣.០៤២ | ១១.៧៣៨ |
| ២០១៧ | ៨៨ | ៧.២៩៦ | ៥.១២៩ |
| សរុប | ៣៦៨ | ៧៥.៨០៥ | ៦៦.៧៨៧ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម (បសស)*

**តារាងទី៩៖ វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីការការពារ ការដួលសន្លប់នៅកន្លែងធ្វើការ**

| ឆ្នាំ | បណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី ការការពារ ការដួលសន្លប់នៅកន្លែងធ្វើការ | |
|---|---|---|
| | ចំនួនអ្នកចូលរួម | វិញ្ញាបនបត្រ |
| ២០១៦ | ៤២៩ (ស្រី២៦០) | ៤២៩ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម(បសស)*

### ៧.៥. ការបណ្ដុះបណ្ដាលសុវត្ថិភាព និងសុខភាពការងារ រៀបចំដោយអង្គការនិយោជក និងអង្គការកម្មករនិយោជិត

អង្គការនិយោជក និងអង្គការកម្មករនិយោជិត បាននិងកំពុងផ្ដល់ការបណ្ដុះបណ្ដាលជាមួយនឹងការភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំជាមួយរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ ប្រធានបទនៃការបណ្ដុះបណ្ដាលឆ្លុះបញ្ចាំងអំពីផលប្រយោជន៍ស្ដីពីសុវត្ថិភាព និងសុខភាពការងារក្នុងប្រទេសកម្ពុជា នៅផ្នែកវាយនភណ្ឌកាត់ដេរ បានក្លាយជាវិស័យដ៏សំខាន់មួយ ។ សុវត្ថិភាព និងសុខភាពការងារក្នុងរោងចក្រ អាហាររូបត្ថម្ភ និងសុខភាពបន្តពូជ ចំពោះកម្មករ កម្មការិនីវ័យក្មេង ជំងឺអេដស៍ និងគ្រឿងញៀន ភាគច្រើនគឺជាចំណុចដែលគេតែងតែលើកឡើងជាប្រធានបទបណ្ដុះបណ្ដាល ។

❖ អង្គការនិយោជក

អង្គការនិយោជក បានធ្វើការបណ្ដុះបណ្ដាលទៅលើការអភិវឌ្ឍជំនាញផ្នែកសុវត្ថិភាព និងសុខភាពការងារ សម្រាប់និយោជក និងកម្មករនិយោជិត ដែលជាស្ថាប័នតំណាងសហព័ន្ធនិយោជក និង

សមាគមពាណិជ្ជកម្មកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានចំណងស្ថាប័នរឹងមាំ ដើម្បីចែកចាយ ព័ត៌មាន និងគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាពការងារ។

❖ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

ចាប់តាំងពីឆ្នាំ២០០៧ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ដោយសហការជាមួយអង្គការអន្តរជាតិ។ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា បានធ្វើការបណ្តុះបណ្តាលជាង ៦០០វគ្គ និងមានអ្នកចូលរួមលើសពី ១០,០០០នាក់។ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលដោយសហការជាមួយសមាគមសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅក្រៅប្រទេស និងភាពជាដៃគូប្រកបដោយនិរន្តរភាព (AOTS) នៅប្រទេសជប៉ុន ប្រហែល ៦វគ្គ ក្នុងមួយឆ្នាំ ដែលមានសមាជិកអាចចូលរួមបានក្រោមអាហារូបករណ៍ផ្តល់ដោយ AOTS ។

❖ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

សមាគមរោងចក្រកាត់ដេរនៅកម្ពុជាផ្តល់នូវវគ្គបណ្តុះបណ្តាលជាច្រើនផ្នែកដល់សមាជិករបស់ខ្លួនក្នុងនោះផ្នែកសុវត្ថិភាព និងសុខភាពការងារ ត្រូវបានបញ្ចូលក្នុងវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការងារ ។ ការបណ្តុះបណ្តាលអំពី ចំណេះដឹងមូលដ្ឋានស្តីពីសុវត្ថិភាព និងសុខភាពការងារ វិធានការការពារ និងសំណង ត្រូវបានគ្របដណ្តប់ ដែលមានរយៈពេល៨ម៉ោង។ ដោយមានការសហការជាមួយអង្គការយ៉េរ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ក៏បានផ្តល់ការបណ្តុះបណ្តាលផងដែរស្តីពីយេនឌ័រ អំពើហិង្សា ការបៀតបៀនផ្លូវភេទដល់កម្មករនិយោជិតក្នុងរោងចក្រកាត់ដេរ។

❖ អង្គការកម្មករនិយោជិត

សហជីពមូលដ្ឋាន បានរៀបចំការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍជំនាញផ្នែកសុវត្ថិភាព និងសុខភាពការងារ ដល់កម្មករនិយោជិត និងពង្រីកប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារមូលដ្ឋានដោយគំនិតផ្តួចផ្តើមនៃកម្មករនិយោជិត និងនិយោជក។ សហជីពមូលដ្ឋាន បានចូលរួមចំណែកយ៉ាងច្រើនក្នុងការពង្រីកការបណ្តុះបណ្តាលសុវត្ថិភាព និងសុខភាពការងារដល់កម្មករនិយោជិត ឧទាហរណ៍ការសហការរវាងរាជរដ្ឋាភិបាល អង្គការអន្តរជាតិខាងការងារ សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា និងសហភាពចលនាកម្មករកម្ពុជាបានរៀបចំកម្មវិធីបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការនៅការដ្ឋានសំណង់ខ្នាតតូចដែលមានកម្មករនិយោជិតជាង ២៧០នាក់ ចូលរួមក្នុងឆ្នាំ២០១៨-២០១៩។ សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា បានផ្តល់នូវកម្មវិធីបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងសុខភាពការងារ នៅក្នុងឧស្សាហកម្មចំណីអាហារ ដោយមានការគាំទ្រពីប្រជាជនអូស្ត្រាលីសម្រាប់ការអប់រំសុខភាព និងការអភិវឌ្ឍនៅក្រៅប្រទេស ។

## ៨. ប្រព័ន្ធសំណងគ្រោះថ្នាក់ការងារ និងជំងឺ

### ៨.១. យន្តការ និងការទទួលខុសត្រូវរបស់ស្ថាប័ន

ការទទួលខុសត្រូវក្នុងការជំរុញការការពារគ្រោះថ្នាក់ការងារ និងជំងឺនានា គឺស្ថិតនៅក្រោម បេឡាជាតិសន្តិសុខសង្គម។ បេឡាជាតិសន្តិសុខសង្គម គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវ បង្កើតដោយព្រះរាជក្រិត្យ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យការងារ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការចុះបញ្ជិកាវោងចក្រ សហគ្រាស និងកម្មករនិយោជិតចូលទៅក្នុង បេឡាជាតិសន្តិសុខសង្គម គឺ ចាំបាច់សម្រាប់និយោជកទាំងអស់ ។ ការចុះបញ្ជិកាសហគ្រាសថ្មីត្រូវធ្វើក្នុងរយះពេល៣០ថ្ងៃ។

ចាប់តាំងពីឆ្នាំ២០០៨-២០១៧ រោងចក្រ សហគ្រាសសរុបចំនួន ១០.៨៤៩ មានកម្មករសរុប ចំនួន ១,៤៣៤,៣១៦នាក់ បានចុះបញ្ជិកាជាសមាជិកនៅបេឡាជាតិសន្តិសុខសង្គម។ រោងចក្រ សហគ្រាស ភាគច្រើនជារោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង និងផ្នែកសេវាកម្ម (សណ្ឋាគារ និងភោជនីយដ្ឋាន)។

### ៨.២. វិសាលភាព

បេឡាជាតិសន្តិសុខសង្គម គឺជាប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមសាធារណៈ ដែលគ្រប ដណ្តប់លើជំងឺវិជ្ជាជីវៈ និងគ្រោះថ្នាក់ការងារ ក្នុងម៉ោងធ្វើការ និងក្នុងពេលធ្វើដំណើរ។ វិសាលភាពនៃ របបសន្តិសុខសង្គមមានដូចខាងក្រោម៖

- សេវាថែទាំសុខភាពសម្រាប់គ្រោះថ្នាក់ការងារ
- ការផ្តល់ប្រាក់ឈ្នួលប្រចាំថ្ងៃ ក្នុងករណីបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន
- ការផ្តល់ប្រាក់ឈ្នួល ឬប្រាក់បំណាច់ សម្រាប់ជនពិការ ក្នុងករណីបាត់បង់សមត្ថភាពការងារ ជាអចិន្ត្រៃយ៍
- ការផ្តល់វិភាជន៍បូជាសព និងតាវកាលិកឧត្តរជីវី ក្នុងករណីមរណភាព។

អត្រាភាគទាននៃការចូលរួមចំណែកសម្រាប់របបសន្តិសុខសង្គម គឺជាអត្រាដែលបានកំណត់ ចំនួន ០.៨% នៃប្រាក់ឈ្នួលជាប់ភាគទានរបស់កម្មករ។ ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការបង់ភាគទានផ្នែកហានិភ័យការងារ មានចំនួនកើនឡើងទៅតាមវិសាលភាពនៃរបបសន្តិសុខសង្គម និងនិយោជកចាំបាច់ត្រូវបង់ភាគទានផ្សេងៗគ្នា។

**តារាងទី១០៖ ការចំណាយសម្រាប់គ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងការដួលសន្លប់**

| ឆ្នាំ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|---|
| សរុបការចំណាយ (គិតជាប៊ីលានរៀល) | ៤.០៩ | ៥.០៦ | ៦.៩២ | ៩.៥៥ | ១២.១៥ | ១៥.៨៣ | ៤៦.០៦ | ១៨៧.៨៤ |
| គ្រោះថ្នាក់ការងារ | ៤.០៩ | ៥.០៦ | ៦.៩២ | ៩.៥៥ | ១២.១៥ | ៧៩.៦ | ១៩.៥២ | ២០.៥៣ |
| | - | - | - | - | - | ៧.៨៦ | ២៦.៥៤ | ១៦៧.៣១ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម(បសស)*

## ៨.៣ បញ្ជីគ្រោះថ្នាក់ការងារ និងរបួស

៨.៣.១. ចំនួនកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ការងារ មានជំងឺ និងស្លាប់ដែលបានចុះឈ្មោះ

ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ គ្រោះថ្នាក់ការងារ និងរបួសមានចំនួន ២៣៧,៤២១ ករណី ត្រូវបានរាយការណ៍ពីរោងចក្រ សហគ្រាស។ ក្នុងចំណោមគ្រោះថ្នាក់ និងរបួសសរុបដែលបានចុះបញ្ជី នៅចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ មានចំនួន ១៧១,៥២១ករណី ត្រូវបានរាយការណ៍ជាគ្រោះថ្នាក់ការងារ។ ក្នុងរយៈពេលនោះ ចំនួនអ្នកទទួលរងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ បានកើនឡើងនៅពេលដែលចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកាក៏មានការកើនឡើងដូចគ្នា។ បន្ទាប់ពីឆ្នាំ២០១៨ ចំនួនអ្នករងរបួសនៅកន្លែងធ្វើការមានការថយចុះបន្តិចម្តងៗ។ ការថយចុះនេះ អាចត្រូវបានចូលរួមដោយវិធីសាស្ត្រជាក់លាក់នៃសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការនៅក្នុងវិស័យ ដែលមានហានិភ័យខ្ពស់ដូចជាវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង។

យោងលើទិន្នន័យដែលបានរាយការណ៍ បេឡាជាតិសន្តិសុខសង្គម បានរៀបចំកម្មវិធីបណ្តុះបណ្តាល និងកិច្ចប្រជុំជាច្រើនដែលផ្តោតសំខាន់លើការការពារគ្រោះថ្នាក់ការងារ និងការរងរបួស។ កម្មវិធីពិសេសសម្រាប់ការការពារករណីដួលសន្លប់ និងគ្រោះថ្នាក់ចរាចរណ៍ត្រូវបានយកចិត្តទុកដាក់។

**តារាងទី១១៖ ករណីស៊ើបអង្កេតនៃចំនួនអ្នករងរបួស និងស្លាប់ដោយគ្រោះថ្នាក់ការងារក្នុងមួយឆ្នាំ**

| ឆ្នាំ | ចំនួនកម្មករដែលបានចុះបញ្ជិកា | ចំនួនគ្រោះថ្នាក់ការងារដែលបានរាយការណ៍ | ភាគរយគ្រោះថ្នាក់ការងារ(%) | ស្លាប់ | ភាគរយស្លាប់(%) |
|---|---|---|---|---|---|
| ២០១១ | ៦៧៤,២១៧ | ១២,៥៧១ | ១.៨៦ | ៤៧ | ០.០០៧ |
| ២០១២ | ៧៦៨,១៣៤ | ១៤,២៣៣ | ១.៨៥ | ៥៩ | ០.០០៨ |
| ២០១៣ | ៨៤៧,១៧៥ | ១៦,៧៧៥ | ១.៩៨ | ៩៦ | ០.០១១ |
| ២០១៤ | ១,០២១,៥៨៨ | ១៨,៦៩៩ | ១.៨៣ | ៩៦ | ០.០០៩ |
| ២០១៥ | ១,០៧៧,០៧៩ | ៣០,២៨១ | ២.៨១ | ១៨១ | ០.០១៧ |
| ២០១៦ | ១,១៣៦,២៧១ | ៣៤,៥១៣ | ៣.០៤ | ១៦៨ | ០.០១៥ |
| ២០១៧ | ១,៤៣៥,៣១៦ | ៤៥,៨៨២ | ៣.២០ | ២២២ | ០.០១៦ |
| ២០១៨ | ១,៤៨០,៩៣២ | ៣៣,៧១២ | ២.២៨ | ២០៧ | ០.០១៤ |

| | | | | | |
|---|---|---|---|---|---|
| ២០១៩ | ១,៣២៤,៥៦៥ | ១៩,៤៩០ | ១.៤៧ | ២៦៣ | 0.0២ |
| **សរុប** | ៩,៧៦៥,២៧៧ | ២២៦,១៥៦ | ២.៣២ | ១៣៣៩ | 0.0១៤ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

**រូបភាពទី៤ ចំនួនអ្នករបួសដោយការងារក្នុងមួយឆ្នាំតាមវិស័យនីមួយៗ**




*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

***សំណង់៖***

ស្ថិតិផ្លូវការនៃបញ្ហាសុវត្ថិភាព និងសុខភាពការងារ សម្រាប់វិស័យសំណង់ មានការកើនឡើងគួរឱ្យកត់សម្គាល់ តាមរយៈការស្ទង់មតិដែលធ្វើឡើងក្នុងឆ្នាំ២០១៧ ដោយសហព័ន្ធសហជីពកម្មករសំណង់និងឈើកម្ពុជា បានបង្ហាញថា (១៩%) នៃអ្នកឆ្លើយតបបានរងគ្រោះថ្នាក់ទាក់ទងនឹងការងារ (១៩៦ ករណីក្នុងចំណោមកម្មករ១,០១០នាក់)។ ការស្ទង់មតិមួយផ្សេងទៀតដែលធ្វើឡើងដោយ BWI នៅក្នុងឆ្នាំ២០០៨ ដែលបានបង្ហាញអំពីបញ្ហាសុខភាពការងារចំនួន៧៖ អាបេសស្តូស ឬធូលី ដែលមានហានិភ័យ(៦៧.៣%) គ្រោះថ្នាក់ទាក់ទងនឹងការងារ(៤០.៦%) សារធាតុគីមី(២៩.៧%) ជំងឺឆ្លង (២២.៨%) កង្វះរបាំងការពារសុវត្ថិភាពម៉ាស៊ីន(១៨.៨%) ការប្រើប្រាស់ឧបករណ៍គ្មានសុវត្ថិភាព និងស្ត្រេសការងារ(៧.៩%) កន្លែងធ្វើការគ្មានអនាម័យ(៥.៩%) និងផ្សេងៗ(៥%)។

៨.៣.២. ការអង្កេតចំនួនគ្រោះថ្នាក់ការងារ និងស្លាប់ប្រចាំឆ្នាំ

យោងតាមស្ថិតិដែលផ្តល់ដោយបេឡាជាតិសន្តិសុខសង្គម ៧០% នៃកម្មករនិយោជិតមានគ្រោះថ្នាក់ការងារ ភាគច្រើននៃស្ត្រីធ្វើការក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ អាចជាហេតុផលមួយដែលចំនួនស្ត្រីមានគ្រោះថ្នាក់ច្រើន។ ទោះយ៉ាងណា ភាគរយនៃគ្រោះថ្នាក់ការងារស្ត្រី បានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៧។ គម្រោងសុវត្ថិភាព និងសុខភាពការងារជាច្រើនដែលមានប្រសិទ្ធភាពបានផ្តោតលើកម្មការិនីនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ វាហាក់ដូចជាបានរួមចំណែកដល់ការថយចុះនៃគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ។

**តារាងទី១២៖ ការអង្កេតចំនួនគ្រោះថ្នាក់ការងារ**

| ឆ្នាំ | គ្រប់វិស័យ | ប្រុស | ស្រី | ភាគរយស្រី(%) |
|---|---|---|---|---|
| ២០១១ | ១២,៥៧១ | ២,៨៣៧ | ៩,៧៣៤ | ៧៧.៤៣ |
| ២០១២ | ១៤,២៣៣ | ៣,៥២៤ | ១០,៧០៩ | ៧៥,២៤ |
| ២០១៣ | ១៦,៧៧៥ | ៤,៧៤៥ | ១២,០៣០ | ៧១.៧១ |
| ២០១៤ | ១៨,៦៩៩ | ៤,៨៧៩ | ១៣,៨២០ | ៧៣.៩១ |
| ២០១៥ | ៣០,២៨១ | ៨,០០៨ | ២២,២៧៣ | ៧៣.៥៥ |
| ២០១៦ | ៣៤,៥១៣ | ៨,៨៣០ | ២៥,៦៨៣ | ៧៤.៤២ |
| ២០១៧ | ៤៥,៨៨២ | ១១,១០៩ | ៣៤,៧៧៣ | ៧៥.៧៩ |
| ២០១៨ | ៣៣,៧១២ | ៩,០៩៣ | ២៤,៦១៩ | ៧៣.០៣ |
| ២០១៩ | ១៩,៤៩០ | ៦,៩៦១ | ១២,៥២៩ | ៦៤.២៨ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

ការបារម្ភទាក់ទងនឹងការស្លាប់របស់កម្មករជាបុរសមានចំនួនភាគច្រើន។ លើសពីនេះទៀត ចំនួនអ្នកស្លាប់បានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០១៤។ ការវាយតម្លៃបន្ថែមទៀត រួមទាំងការសិក្សាតាមវិស័យ និងសកម្មភាពរបស់សុវត្ថិភាព និងសុខភាពការងារត្រូវបានសង្កត់ធ្ងន់។

**តារាងទី១៣៖ ករណីគ្រោះថ្នាក់ការងារបណ្តាលឱ្យស្លាប់តាមភេទ**

| ឆ្នាំ | សរុប | ប្រុស | ស្រី | ភាគរយស្រី (%) |
|---|---|---|---|---|
| ២០១១ | ៤៧ | ៣២ | ១៥ | ៣១.៩ |
| ២០១២ | ៥៩ | ៣៧ | ២២ | ៣៧.៣ |
| ២០១៣ | ៩៦ | ៦៦ | ៣០ | ៣១.៣ |
| ២០១៤ | ៩៦ | ៦៩ | ២៧ | ២៨.១ |
| ២០១៥ | ១៨១ | ១១៤ | ៦៧ | ៣៧.០ |
| ២០១៦ | ១៦៨ | ១០៨ | ៦០ | ៣៥.៧ |
| ២០១៧ | ២២២ | ១៤៩ | ៧៣ | ៣២.៩ |
| ២០១៨ | ២០៧ | ១៤១ | ៦៦ | ៣១.៩ |
| ២០១៩ | ២៦៣ | ១៩១ | ៧២ | ២៧.៤ |
| **សរុប** | **១,៣៣៩** | **៩០៧** | **៤៣២** | **៣២.៣** |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

៨.៣.៣. ការអង្កេតចំនួនគ្រោះថ្នាក់ការងារប្រចាំឆ្នាំសម្រាប់រោងចក្រ សហគ្រាស

តារាងទី១៥៖ បង្ហាញពីចំនួនកម្មករដែលបានចុះបញ្ជិកា ចំនួនគ្រោះថ្នាក់ ចំនួនពិការភាព និងស្លាប់ តាមឆ្នាំនិងតាមវិស័យ។ ជារៀងរាល់ឆ្នាំវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង មានប្រហែល ៦០-៧០% ទទួលរងគ្រោះថ្នាក់ការងារ។ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ចំនួនគ្រោះថ្នាក់ការងារ ត្រូវបានថយចុះគួរឱ្យកត់សម្គាល់ ទន្ទឹមនឹងនេះ ភាគរយនៃអ្នកស្លាប់ និងរបួសធ្ងន់ធ្ងរក្នុងវិស័យសំណង់ហាក់ដូចជាមានការកើនឡើងខ្ពស់បើប្រៀបធៀបទៅនិងវិស័យផ្សេងទៀត។ ការរាយការណ៍អំពីគ្រោះថ្នាក់ការងារនៅក្នុងវិស័យសំណង់នៅមានកម្រិត ដោយត្រូវការពេលវេលាបន្ថែមសម្រាប់ការប្រមូល និងវិភាគទិន្នន័យគ្រោះថ្នាក់ការងារក្នុងវិស័យនេះ។

**តារាងទី១៤៖ ការអង្កេតចំនួនគ្រោះថ្នាក់ការងារតាមវិស័យនីមួយៗ**

| ឆ្នាំ | វិស័យទាំងអស់ | កាត់ដេរ សម្លៀកបំពាក់ | % | ស្បែកជើង | % | សំណង់ | % | កសិកម្ម | % |
|---|---|---|---|---|---|---|---|---|---|
| ២០១១ | ១២,៥៧១ | ៨,៧៤១ | ៦៩.៥ | ១,២០២ | ៩.៦ | ២២ | 0.២ | ២៨ | 0.២ |
| ២០១២ | ១៤,២៣៣ | ៩,៦៧១ | ៦៧.៩ | ១,៣២៥ | ៩.៣ | ២៧ | 0.២ | ៤៧ | 0.៣ |
| ២០១៣ | ១៦,៧៧៥ | ៩,៧៦៣ | ៥៨.២ | ២,២៤៨ | ១៣.៥ | ១១ | 0.១ | ៥៥ | 0.៣ |
| ២០១៤ | ១៨,៦៩៩ | ១១,១៨០ | ៥៩.៨ | ៣,៣៩១ | ១៨.១ | ៣៣ | 0.២ | ៩២ | 0.៥ |
| ២០១៥ | ៣០,២៨១ | ១៦,៤៧០ | ៥៤.៤ | ៤,៦៩៥ | ១៥.៥ | ៤៩ | 0.២ | ២១៥ | 0.៧ |
| ២០១៦ | ៣៤,៥១៣ | ១៩,០៣៥ | ៥៥.២ | ៥,០៣៥ | ១៤.៦ | ៨២ | 0.២ | ១៨៨ | 0.៥ |
| ២០១៧ | ៤៥,៨៨២ | ២៤,២៩៦ | ៥៣.០ | ៦,៣៤៣ | ១៣.៨ | ១២០ | 0.៣ | ១៤៣ | 0.៣ |
| ២០១៨ | ៣៣,៧១២ | ១៧,៤៦៨ | ៥១.៨ | ៤,៨៦២ | ១៤.៤ | ១២៥ | 0.៤ | ១៤៣ | 0.៤ |
| **សរុប** | **២០៦,៦៦៦** | **១១៦,៦២៤** | **៥៦.៤** | **២៩,១០១** | **១៤.១** | **៤៦៩** | **0.២** | **៩១១** | **0.៤** |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

**តារាងទី១៥៖ ការអង្កេតចំនួនគ្រោះថ្នាក់ការងារតាមវិស័យនីមួយៗ**

| ឆ្នាំ / វិស័យ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|---|
| **កាត់ដេរ សំម្លៀក បំពាក់** | ៨,៧៤១ | ៩,៦៧១ | ៩,៧៦៣ | ១១,១៨០ | ១៦,៤៧០ | ១៩,០៣៥ | ២៤,២៩៦ | ១៧,៤៦៨ | ១១៦,៦២៤ |
| ប្រុស | ១,៣១៩ | ១,៥១១ | ១,៨៦០ | ១,៨៥១ | ២,៩៣៣ | ៣,១៦១ | ៣,៥៤៤ | ៣,០១៨ | ១៩,១៩៧ |
| ស្រី | ៧,៤២២ | ៨,១៦០ | ៧,៩០៣ | ៩,៣២៩ | ១៣,៥៣៧ | ១៥,៨៧៤ | ២០,៧៥២ | ១៤,៤៥០ | ៩៧,៤២៧ |
| **ស្បែកជើង** | ១,២០២ | 1,៣២៥ | ២,២៤៨ | ៣,៣៩១ | ៤,៦៩៥ | ៥,០៣៥ | ៦,៣៤៣ | ៤,៨៦២ | ២៩,១០១ |
| ប្រុស | ១៣៦ | ២០៦ | ៣១០ | ៤៥៤ | ៦១៥ | ៧០៥ | ៨៦០ | ៧១២ | ៣,៩៩៨ |
| ស្រី | ១,០៦៦ | ១,១១៩ | ១,៩៣៨ | ២,៩៣៧ | ៤,០៨០ | ៤,៣៣០ | ៥,៤៨៣ | ៤,១៥០ | ២៥,១០៣ |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

## តារាងទី១៦៖ ចំនួនពិការភាពតាមវិស័យក្នុងឆ្នាំនីមួយៗ

